ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា



នីតិកាលទី២ (២០០៦-២០១២)

ឱបត្តម្ភដោយ : គំរោងគាំទ្រនីតិប្បញ្ញត្តិ កម្ពុជា-កាណាដា (CCLSP)
ខែ កុម្ភៈ ឆ្នាំ ២០០៧

ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា



ទីតិកាលទី២ (២០០៦-២០១២)

ឯកសារនេះត្រូវបានបោះពុម្ពដោយ : គំរោងគាំទ្រនីតិប្បញ្ញត្តិ កម្ពុជា-កាណាដា (CCLSP)
ខែ កុម្ភៈ ឆ្នាំ ២០០៧



សម័យប្រជុំដំបូងព្រឹទ្ធសភានីតិកាលទី២

ថ្ងៃទី ២០ ខែមីនា ឆ្នាំ២០០៦



រូបថតអនុស្សាវរីយ៍ពេលសិប្បាប្រណិធានទៅព្រះបរមរាជវាំង

ថ្ងៃទី ២០ ខែមីនា ឆ្នាំ២០០៦

អារម្ភកថា

ការរៀបចំសៀវភៅស្តីពី នីតិកាលទី២ នៃព្រឹទ្ធសភា (២០០៦-២០១២) ផ្តោតទៅលើ : តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា ការរៀបចំ និងការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា នីតិវិធីពិនិត្យ និងឱ្យយោបល់លើ អត្ថបទច្បាប់ តារាងរាយនាមគណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការជំនាញនានានៃព្រឹទ្ធសភា និងតារាង រាយនាមរបស់សមាជិកា សមាជិកព្រឹទ្ធសភា តាមលំដាប់អក្សរ តាមលំដាប់អាយុ តាមភូមិភាគ តាម គណបក្ស និងរចនាសម្ព័ន្ធថ្មីរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។

ការចងក្រងសៀវភៅនេះមួយភាគធំ ត្រូវបានរៀបចំឡើងទៅតាមព័ត៌មានដែលសមាជិកា សមាជិក ព្រឹទ្ធសភានីតិកាលទី២ (២០០៦-២០១២) ផ្តល់ឱ្យ និងលទ្ធផលជាផ្លូវការប្រកាសដោយគណៈកម្មាធិការ ជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) នាថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៦ ព្រមទាំងឯកសារជាមូលដ្ឋានផ្សេងទៀត របស់ព្រឹទ្ធសភា ។

អគ្គលេខាធិការដ្ឋាន សូមសង្ឃឹមជឿជាក់ថា សៀវភៅឯកសារនេះនឹងមានសារៈសំខាន់ជួយដល់ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋាននៅក្នុងការប្រតិបត្តិការងារប្រចាំថ្ងៃ។ ជាមួយគ្នានោះ សាធារណៈជនទូទៅ នឹងអាចមានភាពងាយស្រួល ដើម្បីស្វែងយល់អំពីស្ថាប័នព្រឹទ្ធសភានា នីតិកាលទី២នេះ ។

ព្រឹទ្ធសភានីតិកាលទី២ បានចាប់ចេញដំណើរតាំងពីថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០៦ ជាមួយនឹងបទ-បញ្ជាផ្ទៃក្នុងថ្មីដែលមានចរិតស្របទៅតាមស្តង់ដារ នៃសភាប្រជាធិបតេយ្យលើពិភពលោកយើងនាពេល បច្ចុប្បន្ននេះ ។

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកំពុងដំណើរការយ៉ាងសកម្មតាមរចនាសម្ព័ន្ធក្នុងក្របខ័ណ្ឌ នៃផែនការ យុទ្ធសាស្ត្រ៥ឆ្នាំ និងគោលនយោបាយគ្រប់គ្រងថ្មី ។

ឯកសារប្រមូលផ្តុំនេះនឹងឆ្លុះបញ្ចាំងឱ្យឃើញនូវទិដ្ឋភាពថ្មីៗ នៃនីតិកាលទី២ របស់ព្រឹទ្ធសភា (២០០៦-២០១២) ដែលខុសប្លែកពីនីតិកាលទី១ (១៩៩៩-២០០៥) ។

ភ្នំពេញ, ខែ កុម្ភៈ ឆ្នាំ ២០០៧

មាតិកា

ល.រ	ចំណងជើងអត្ថបទ	ទំព័រ
	រូបថតសម័យប្រជុំដំបូងព្រឹទ្ធសភានីតិកាលទី ២ និងរូបថតអនុស្សាវរីយ៍ពេលសច្ចាប្រណិធាននៅព្រះបរមរាជវាំង	
	អារម្ភកថា	
	ប្រវត្តិព្រឹទ្ធសភា	១
១	ការរៀបចំ និងការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា	១
២	តួនាទី និង ភារកិច្ចរបស់ព្រឹទ្ធសភា	៣
៣	ភាពឧុសគ្នារវាងរដ្ឋសភា និងព្រឹទ្ធសភា	៤
៤	នីតិវិធីពិនិត្យ និងឱ្យយោបល់លើអត្ថបទច្បាប់ ឬ បញ្ហានានា	៧
៥	គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា	១២
៦	តួនាទី ភារកិច្ចរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភានីតិកាលទី ២ (២០០៦-២០១២)	១៣
៧	បញ្ជីរាយនាមសមាជិកា សមាជិកព្រឹទ្ធសភាតាមលំដាប់អក្ខរក្រមខ្មែរ	១៥
៨	បញ្ជីរាយនាមសមាជិកា សមាជិកព្រឹទ្ធសភាតាមលំដាប់អាយុពីខ្ពស់មកទាប	១៨
៩	បញ្ជីរាយនាមសមាជិកា សមាជិកព្រឹទ្ធសភានីតិកាលទី ២ តាមមណ្ឌលភូមិភាគ	២១
១០	ស្ថិតិអំពីសមាជិកា សមាជិកព្រឹទ្ធសភានីតិកាលទី ២ (២០០៦-២០១២)	២៥
១១	បញ្ជីរាយនាមសមាជិកា សមាជិកព្រឹទ្ធសភានីតិកាលទី ២ តាមគណបក្ស	២៧
១២	បញ្ជីរាយនាមសមាជិកា សមាជិកព្រឹទ្ធសភានីតិកាលទី២ តាមគណៈកម្មការ អក្សរ-ឡាតាំង ហ៊ានៈ	៣០
១៣	សមាសភាពគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភានីតិកាលទី ២ (២០០៦-២០១២)	៣៤
១៤	សមាសភាព និងតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់គណៈកម្មការជំនាញទាំង ៩ នីតិកាលទី ២ (២០០៦-២០១២)	៣៥
១៥	សមាសភាពសមាជិកា សមាជិកក្រៅគណៈកម្មការ	៥៨
១៦	សមាសភាពក្រុមមិត្តភាព និងលក្ខន្តិកៈក្រុមមិត្តភាព	៥៩
១៧	បញ្ជីឈ្មោះសមាជិកា សមាជិកព្រឹទ្ធសភា និងស្លាកលេខរថយន្តព្រឹទ្ធសភានីតិកាលទី២	១២២

១៨	បញ្ជីឈ្មោះសមាជិកា សមាជិកព្រឹទ្ធសភា និងលេខទូរស័ព្ទ នីតិកាលទី២	១២៥
១៩	បញ្ជីរាយនាមសមាជិកព្រឹទ្ធសភា ជំនួយការផ្ទាល់ និងអ្នកបើកបរ	១២៨
២០	សញ្ញាសក្តិ និងឯកសណ្ឋានរបស់សមាជិកា សមាជិកព្រឹទ្ធសភា	១៣១
២១	ប្រវត្តិរូបសង្ខេបរបស់សមាជិកា សមាជិកព្រឹទ្ធសភាទាំង ៦១ រូប សំរាប់នីតិកាលទី ២	១៣៧
២២	អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា	២២៩
២៣	តួនាទី ភារកិច្ច និងសមាសភាពថ្នាក់ដឹកនាំខុទ្ទកាល័យព្រឹទ្ធសភា	២៣២
២៤	តួនាទី ភារកិច្ចរបស់នាយកដ្ឋាន និងសមាសភាពថ្នាក់ដឹកនាំតាមនាយកដ្ឋាន នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា	២៣៤
២៥	ព័ត៌មានរូបភាព	២៩១
២៦	បួងអាគារក្នុងបរិវេណមន្ទីរព្រឹទ្ធសភា	២៩៥

ប្រវត្តិព្រឹទ្ធសភា

ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតឡើងបន្ទាប់ពីកិច្ចប្រជុំរវាងថ្នាក់ដឹកនាំជាន់ខ្ពស់គណបក្សនយោបាយធំៗទាំងពីរ នាថ្ងៃទី១២ និងទី១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** នៅព្រះបរមរាជវាំង ក្នុងគោលបំណងបញ្ចប់វិបត្តិនយោបាយ លើកកំពស់ការបង្រួបបង្រួមផ្ទៃផ្ទៃផ្ទៃជាតិ និងពង្រឹងស្ថិរភាពនយោបាយ ដោយបានឯកភាពធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា តាមច្បាប់ធម្មនុញ្ញដែលបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ១៩៩៩។

ការបង្កើតស្ថាប័នព្រឹទ្ធសភានេះ គឺជាព្រឹត្តិការណ៍នយោបាយដ៏សំខាន់មួយក្នុងប្រវត្តិសាស្ត្រកម្ពុជា ដែលបានបង្ហាញឱ្យឃើញនូវពន្លឺថ្មីមួយសម្រាប់អនាគតនៃប្រទេសកម្ពុជា ដើម្បីស្ថិរភាពផ្ទៃកនយោបាយ ព្រមទាំងបង្ហាញឱ្យឃើញពីការប្តេជ្ញាចិត្តជាបន្តបន្ទាប់ក្នុងការកសាងលទ្ធិប្រជាធិបតេយ្យ និងការពង្រឹងនីតិរដ្ឋ។ ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានបើកសម័យប្រជុំដំបូង នីតិកាលទី១ នាថ្ងៃទី ២៥ ខែមីនា ឆ្នាំ១៩៩៩។

ព្រឹទ្ធសភានីតិកាលទី១ (១៩៩៩-២០០៥) បានផ្តួចផ្តើមគំនិតធ្វើច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាសម្រាប់នីតិកាលបន្តបន្ទាប់ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៣។ ព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១។ បន្ទាប់មកក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញតាមសេចក្តីសំរេចលេខ ០៧០/០០២/ ២០០៥ កបធ.ច ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០០៥។ ច្បាប់នេះ ត្រូវបានប្រមុខរដ្ឋស្តីទីប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៦០៥/០២០ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០០៥។

១. ការរៀបចំ និងការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា

១.១.ការរៀបចំព្រឹទ្ធសភា

ការបោះឆ្នោតជ្រើសតាំងសមាជិកា សមាជិកព្រឹទ្ធសភានីតិកាលទី២ បានប្រព្រឹត្តទៅនាថ្ងៃទី ២២ ខែមករា ឆ្នាំ២០០៦។ សម្រាប់នីតិកាលទី២នេះ ចំនួនសមាជិកព្រឹទ្ធសភាមាន ៦១រូប (ដូចនីតិកាលទី១) ក្នុងនោះមានសមាជិកា ០៥រូប។ សមាជិក ០២រូប តែងតាំងដោយព្រះមហាក្សត្រ ០២រូប ជ្រើសតាំងដោយរដ្ឋសភា ៥៧រូប ជ្រើសតាំងដោយការបោះឆ្នោត ។ ក្នុង៥៧រូបនេះមាន ៤៥រូប មកពីគណបក្សប្រជាជនកម្ពុជា ១០រូប មកពីគណបក្សហ៊្វុនស៊ិនប៉ិច និង០២រូប មកពីគណបក្សសម រង្ស៊ី។

អង្គការដឹកនាំដ៏សំខាន់មួយរបស់ព្រឹទ្ធសភា គឺគណៈកម្មាធិការអចិន្ត្រៃយ៍ដែលមានសមាសភាព១២រូប។

ព្រឹទ្ធសភាមានគណៈកម្មការជំនាញចំនួន៩ :

១-គណៈកម្មការ សិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត

២-គណៈកម្មការ ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម

៣-គណៈកម្មការ សេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និង បរិស្ថាន

៤-គណៈកម្មការ មហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារ សាធារណៈ

៥-គណៈកម្មការ កិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន

៦-គណៈកម្មការ នីតិកម្ម និង យុត្តិធម៌

៧-គណៈកម្មការ អប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ និងទេសចរណ៍

៨-គណៈកម្មការ សុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី

៩-គណៈកម្មការ សាធារណការ ដឹកជញ្ជូន អាកាសចរណ៍ស៊ីវិល ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបណីយកម្ម និង សំណង់

១.២.ការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា

ព្រឹទ្ធសភាប្រជុំជាសាមញ្ញ២ដងក្នុងមួយឆ្នាំ។ សម័យប្រជុំនីមួយៗមានថិរវេលាយ៉ាងតិច៣ខែ។ បើមានសំណូមពរពីព្រះមហាក្សត្រ ឬសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬ ពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគបីយ៉ាងតិច ព្រឹទ្ធសភាកោះប្រជុំជាវិសាមញ្ញ (មាត្រា ១០៧ថ្មី នៃរដ្ឋធម្មនុញ្ញ)។

ការប្រជុំព្រឹទ្ធសភា ត្រូវធ្វើជាសាធារណៈ និងត្រូវផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ជាតិ។ កំណត់ហេតុនៃការប្រជុំព្រឹទ្ធសភា មានកំណត់ហេតុសង្ខេប និងកំណត់ហេតុពិស្តារ។ កំណត់ហេតុទាំងអស់ត្រូវរក្សាទុកនៅក្នុងបណ្ណាល័យព្រឹទ្ធសភា។

ព្រឹទ្ធសភាអាចកោះប្រជុំជាសម្ងាត់បានតាមសំណើសុំពីប្រធាន ឬពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគដប់យ៉ាងតិច ឬពីព្រះមហាក្សត្រ ឬពីនាយករដ្ឋមន្ត្រី ឬពីប្រធានរដ្ឋសភា (មាត្រា ១១១ ថ្មី (ពីរ) នៃរដ្ឋ-ធម្មនុញ្ញ)។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបានលុះត្រាតែមាន :

ក-កូរ៉ុមលើសពី ពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណា ដែលតម្រូវឱ្យយកមតិភាគច្រើន ពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ខ-កូរ៉ុមលើសពីពាក់កណ្តាលនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូលសំរាប់ការអនុម័តទាំងឡាយណា ដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬយកមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

កូរ៉ុមត្រូវតែមានគ្រប់ចំនួននៅពេលបើកការប្រជុំ និងនៅពេលអនុម័ត ។

បើកូរ៉ុមមិនគ្រប់ក្នុងរយៈពេល ៣០នាទី ក្រោយពេលកំណត់ចាប់ផ្តើមការប្រជុំ ប្រធានព្រឹទ្ធសភាត្រូវលើកពេលប្រជុំ (ប្រការ ៥៩ ថ្មី បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា) ។

២. តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា

ព្រឹទ្ធសភាជាអង្គការនីតិប្បញ្ញត្តិរបស់ជាតិ ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការប្រជាធិបតេយ្យ ការវិបនីយកម្មសង្គម និងក្នុងការកសាងកម្ពុជាជានីតិរដ្ឋ។ ព្រឹទ្ធសភាមានមុខងារសំខាន់មួយទៀត គឺការរួមវិភាគទាននៅក្នុងដំណើរការស្ថិរភាវូបនីយកម្មជីវភាពនយោបាយរបស់ជាតិដែលជាស្នូលនៃការពង្រឹងនយោបាយ បង្រួបបង្រួមផ្ទៃផ្ទាជាតិ និងអភិវឌ្ឍន៍ប្រទេសជាតិអោយមានការរីកចំរើនរុងរឿង និងសម្បូណ៌សប្បាយ ។

ព្រឹទ្ធសភាមានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និងរដ្ឋាភិបាល ។

ព្រឹទ្ធសភាពិនិត្យ ហើយឱ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរលើអត្ថបទច្បាប់ ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងលើបញ្ហាទាំងពួងដែលរដ្ឋសភាបានដាក់ឱ្យពិនិត្យ។ បើជាការប្រញាប់រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ ។

បើព្រឹទ្ធសភាបានឱ្យយោបល់ព្រម ឬពុំបានឱ្យយោបល់សោះ ក្នុងរយៈពេលដែលមានកំណត់ទុកហើយនោះទេ ច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះ នឹងត្រូវបានយកទៅប្រកាសឱ្យប្រើ ។

បើព្រឹទ្ធសភាសុំឱ្យកែសម្រួលអត្ថបទច្បាប់នោះ រដ្ឋសភា ត្រូវយកមកពិចារណាភ្លាមជាលើកទីពីរ ។ រដ្ឋសភាត្រូវពិនិត្យ និងសម្រេចតែត្រង់បទប្បញ្ញត្តិ ឬចំណុចណាដែលព្រឹទ្ធសភាសុំឱ្យកែសម្រួលដោយបដិសេធចោលទាំងមូល ឬទុកជាបានការខ្លះ ។

ការបង្ហិលទៅបង្ហិលមករវាងព្រឹទ្ធសភា និងរដ្ឋសភា ត្រូវធ្វើតែក្នុងរយៈពេលមួយខែ ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ថ្ងៃ បើត្រូវពិនិត្យសម្រេចពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែពីរថ្ងៃបើជាការប្រញាប់ ។

បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ ឬពន្យាពេលដែលកំណត់ទុកសម្រាប់ពិនិត្យ នោះរយៈពេលជាគោលការណ៍សម្រាប់រដ្ឋសភា និងព្រឹទ្ធសភាត្រូវបន្ថែមឱ្យស្មើគ្នាដែរ។

បើព្រឹទ្ធសភាបដិសេធអត្ថបទច្បាប់នោះជាអសារបង់ រដ្ឋសភាមិនអាចនឹងយកមកពិចារណាជាលើកទីពីរបានមុនរយៈពេលមួយខែទេ។ រយៈពេលនេះ ត្រូវបន្ថយមកត្រឹមដប់ប្រាំថ្ងៃ បើពិនិត្យពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែបួនថ្ងៃ បើជាការប្រញាប់។

ក្នុងការពិនិត្យអត្ថបទច្បាប់ជាលើកទី២នេះ រដ្ឋសភា ត្រូវអនុម័តដោយវិធីបោះឆ្នោតចំហ និងយកតាមមតិភាគច្រើនដាច់ខាត។

អត្ថបទច្បាប់ណា ដែលបានសម្រេចដូចខាងលើនេះហើយនោះ នឹងត្រូវបានយកទៅប្រកាសឱ្យប្រើ។

៣. តារាងខុសគ្នារវាងរដ្ឋសភា និងព្រឹទ្ធសភា

ព្រឹទ្ធសភា និងរដ្ឋសភា ជាអង្គការមានអំណាចនីតិប្បញ្ញត្តិដូចគ្នា តែរដ្ឋសភា និងព្រឹទ្ធសភាមានអត្តសញ្ញាណ និងសមត្ថកិច្ចខុសគ្នា អាស្រ័យដោយ :

១-ប្រភព :

-តំណាងរាស្ត្រទាំងអស់ ត្រូវជ្រើសតាំងតាមការបោះឆ្នោតសកល ដោយប្រជារាស្ត្រតាមមណ្ឌលខេត្ត-ក្រុង សំរាប់រយៈពេល ៥ ឆ្នាំ។

-សមាជិកព្រឹទ្ធសភា ត្រូវជ្រើសតាំងតាមការបោះឆ្នោតអសកល ដោយក្រុមប្រឹក្សាឃុំ-សង្កាត់ និងតំណាងរាស្ត្រក្នុងតំណែង តាមភូមិភាគសំរាប់រយៈពេល ៦ឆ្នាំ។ រួមជាមួយនោះមាន ២រូប ត្រូវបានតែងតាំងដោយព្រះមហាក្សត្រ និង២រូបទៀត ត្រូវបានជ្រើសតាំងដោយរដ្ឋសភា។ ដូច្នេះ លក្ខណៈពិសេសរបស់ព្រឹទ្ធសភា គឺព្រឹទ្ធសភាកើតដោយការបោះឆ្នោតជ្រើសតាំងផង និងដោយការតែងតាំងផង។

២-ភាពតំណាង :

- **តំណាងរាស្ត្រ** : ជាតំណាងរបស់ប្រជាពលរដ្ឋទូទៅជាម្ចាស់ឆ្នោតក្នុងមណ្ឌល។ បេក្ខជនតំណាងរាស្ត្រមានអាយុយ៉ាងតិច ២៥ឆ្នាំ។
- **សមាជិកព្រឹទ្ធសភា** : ភាគច្រើនជាតំណាងក្រុមប្រឹក្សាឃុំ-សង្កាត់ដែលជាម្ចាស់ឆ្នោតនៅក្នុងភូមិភាគ។ ប៉ុន្តែក៏មានតំណាងព្រះមហាក្សត្រ និងមានតំណាងរដ្ឋសភាដែរនៅក្នុងព្រឹទ្ធសភា។ វត្តមាននៃតំណាងស្ថាប័នជាន់ខ្ពស់ទាំងពីរនេះ រួមទាំងភាពតំណាងសមូហភាពដែនដីធ្វើឱ្យស្ថាប័នព្រឹទ្ធសភាមាន

តួនាទីពិសេស ជាស្ថានតក្លាប់អំណាចរបស់រដ្ឋ ពីថ្នាក់ខ្ពស់ទៅដល់ថ្នាក់មូលដ្ឋានជាប់នឹងប្រជារាស្ត្រ។ បេក្ខជនសមាជិកព្រឹទ្ធសភា មានអាយុយ៉ាងតិច ៤០ឆ្នាំ។

គួរកត់សំគាល់ដូចតទៅ :

- ភាពជាតំណាងខុសគ្នា ការយកចិត្តទុកដាក់ក៏ខុសគ្នា។

  មណ្ឌលរបស់តំណាងរាស្ត្រ ជាខេត្ត-ក្រុង។ មណ្ឌលរបស់សមាជិកព្រឹទ្ធសភា ជាភូមិភាគដែលភាគច្រើនជាការប្រមូលផ្តុំខេត្ត-ក្រុងចាប់ពីពីរឡើងទៅ។

- ភាពខុសគ្នាខាងអាយុ ពុំមែនដោយអត់ហេតុផលឡើយ។ ភាពចាស់ទុំខាងនយោបាយ និងបទ-ពិសោធន៍ ប្រកបដោយស្មារតីទទួលខុសត្រូវ និងសីលធម៌ខ្ពស់ជាកត្តាចំបង នៃការជ្រើសរើសសរិត-សំរាំង ព្រោះសមាជិកព្រឹទ្ធសភា ត្រូវជ្រើសតាំងដោយអ្នកជាប់ឆ្នោត និងតែងតាំងដោយព្រះមហា-ក្សត្រ។ នេះក៏ជាចំណុចកត់សំគាល់អំពីភាពខុសគ្នារវាងសភាទាំងពីរ នៅក្នុងការអនុវត្តការងារជាក់-ស្តែង។ ការឱ្យយោបល់ប្រកបដោយគតិបណ្ឌិត ការណែនាំ និងការបង្ហាញផ្លូវដំណោះស្រាយជាការយកចិត្តទុកដាក់របស់ព្រឹទ្ធសភា។

- ភាពខុសគ្នាខាងប្រព័ន្ធបោះឆ្នោត អង្គបោះឆ្នោត រយៈពេលនៃនីតិកាលបង្ហាញនូវលក្ខណៈពិសេសផ្ទាល់ និងអត្តសញ្ញាណផ្ទាល់របស់សភានីមួយៗ។

៣-អំណាច :

ក-រដ្ឋសភាជ្រើសតាំងរដ្ឋាភិបាល

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល (មាត្រា ៩០ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ) និងអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែង (មាត្រា ៩៨ថ្មី នៃរដ្ឋធម្មនុញ្ញ)។ រដ្ឋសភាអាចត្រូវបានរំលាយមុនផុតអាណត្តិ បើសិនរាជរដ្ឋាភិបាលត្រូវបានទម្លាក់ពីរដងក្នុងរយៈពេល ១២ខែ។ ព្រឹទ្ធសភាមិនអាចត្រូវរំលាយមុនចប់អាណត្តិបានទេ។

ខ-សិទ្ធិវិសោធនកម្មរដ្ឋធម្មនុញ្ញ :

មាត្រា ១៥១ ថ្មី នៃរដ្ឋធម្មនុញ្ញ ផ្តល់សិទ្ធិផ្តួចផ្តើមគំនិតសើរើ ឬផ្តួចផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋ-ធម្មនុញ្ញដល់ប្រធានរដ្ឋសភា (តាមសេចក្តីស្នើរបស់តំណាងរាស្ត្រ មួយភាគបួន នៃចំនួនសមាជិករដ្ឋសភាទាំងមូល)។ រដ្ឋធម្មនុញ្ញពុំបានផ្តល់សិទ្ធិផ្តួចផ្តើមគំនិតនេះដល់ប្រធានព្រឹទ្ធសភាទេ។

គ-ការផ្តួចផ្តើមគំនិតធ្វើច្បាប់

សមាជិករដ្ឋសភា ឬសមាជិកព្រឹទ្ធសភា មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ដូចគ្នា។ សេចក្តីស្នើច្បាប់ណា ដែលផ្តួចផ្តើមធ្វើដោយសមាជិកព្រឹទ្ធសភា ត្រូវតែបញ្ជូនទៅឱ្យរដ្ឋសភាអនុម័តជាលើកដំបូងរួចហើយទើបបញ្ជូនមកព្រឹទ្ធសភាពិនិត្យ និងឱ្យយោបល់ស្របតាមមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ។

ឃ-ការត្រួតពិនិត្យលើរដ្ឋាភិបាល :

រដ្ឋសភាមានអំណាចតាមច្បាប់ក្នុងការចោទសួរដេញដោល និងអនុម័តញត្តិបន្ទោស ដកហូតតំណែង ឬរំលាយរាជរដ្ឋាភិបាល។ តែនៅក្នុងជាក់ស្តែងសភាលើពិភពលោក ទោះបីជាមានគណបក្សប្រឆាំងនៅក្នុងរដ្ឋសភាយ៉ាងណាក្តី ការប្រើអំណាចត្រួតពិនិត្យនេះមានប្រសិទ្ធភាពមិនសូវខ្ពស់ទេ ព្រោះរដ្ឋសភាជាអ្នកបង្កើតរដ្ឋាភិបាល ហើយរបបសម្តេងភាគច្រើន តែងតែគាំទ្ររដ្ឋាភិបាល។ ចរិតរបស់រដ្ឋសភា ជាទូទៅជាប់ជំពាក់នឹងនយោបាយដោយមានជម្រើស២ គឺគាំទ្រ ឬក៏ប្រឆាំងរដ្ឋាភិបាល។ សម្រាប់ព្រឹទ្ធសភាចរិតទូទៅ គឺមិនមែនប្រឆាំង ឬគាំទ្ររដ្ឋាភិបាលឡើយ។ ផលិតច្បាប់ឱ្យបានល្អជាគោលដៅអាទិភាពរបស់ព្រឹទ្ធសភា ដោយមិនចំណុះបរិយាកាសនយោបាយ និងកាល:ទេស:ឡើយ។ ព្រឹទ្ធសភាមិនប្រឈមនឹងរដ្ឋាភិបាល ដូចរដ្ឋសភាដោយប្រើញត្តិបន្ទោសដើម្បីដកហូតមុខតំណែងសមាជិករដ្ឋាភិបាល ឬរំលាយរដ្ឋាភិបាលឡើយ។ ជាទូទៅព្រឹទ្ធសភា ជាកូនជញ្ជីង ដើម្បីធ្វើឱ្យច្បាប់មានតុល្យភាព ដែលអាចទទួលយកបានពីរដ្ឋសភា រដ្ឋាភិបាល និងពីសំណាក់ប្រជាពលរដ្ឋ។ គ្មានស្ថាប័នណាមួយទៀតអាចប្រឡូកនៅក្នុងការដ្ឋាននេះឡើយ ក្រៅពីព្រឹទ្ធសភា លើកលែងក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានសិទ្ធិសម្រេចអំពីធម្មនុញ្ញភាពនៃច្បាប់ មុននឹងប្រកាសឱ្យប្រើ ហើយសម្រាប់តែច្បាប់ធម្មនុញ្ញ និងច្បាប់រៀបចំអង្គការតែប៉ុណ្ណោះ។ ដូច្នេះ ច្បាប់ទូទៅត្រូវការសម្តេងយល់ព្រមរបស់ព្រឹទ្ធសភា។

ផ្តើមចេញពីចរិតខុសគ្នានេះ យោបល់ និងការឆ្លុះបញ្ចាំងរបស់ព្រឹទ្ធសភាអាចខុសពីរដ្ឋសភា។ យោបល់និងការឆ្លុះបញ្ចាំងរបស់ព្រឹទ្ធសភា មានទម្ងន់ហើយគ្រប់ជ្រុងជ្រោយ ដោយសារតែព្រឹទ្ធសភាជាតំណាងក្រុម-ប្រឹក្សាឃុំ-សង្កាត់ ដែលជារដ្ឋបាលថ្នាក់ក្រោមបំផុត និងជាអ្នកអនុវត្តន៍ជាមួយប្រជាពលរដ្ឋ នូវរបបវិមជ្ឈការនៅមូលដ្ឋានទូទាំងប្រទេស។

ព្រឹទ្ធសភាអាចធ្វើការទិតៀនតាមរយៈប្រៀបស្ថាបនាលើបញ្ហាជាតិ តាមរយៈដំណើរការសិក្សាស្រាវជ្រាវ វាយតម្លៃ និងកំណត់នូវចក្ខុវិស័យទៅមុខ ព្រមទាំងផ្តល់នូវអនុសាសន៍ ដែលរាជរដ្ឋាភិបាលងាយនឹងទទួលយក។

ង-អំណាចសំរេចចិត្ត :

រដ្ឋសភា និងព្រឹទ្ធសភា អាចប្រជុំរួមគ្នាជាសមាជ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ។

៤-បទប្បញ្ញត្តិពិសេស ចែងក្នុងរដ្ឋធម្មនុញ្ញ

ក-ប្រធានព្រឹទ្ធសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ក្នុងករណីព្រះមហាក្សត្រទ្រង់អវត្តមាន (រដ្ឋធម្ម-នុញ្ញមាត្រា ៣០ថ្មី)។ នៅពេលព្រះមហាក្សត្រទ្រង់ចូលទីវង្គត ឬទ្រង់ប្រឈួនជាទម្ងន់ ប្រធានព្រឹទ្ធសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ក្នុងឋានៈជាព្រះរាជានុសិទ្ធិ នៃព្រះរាជាណាចក្រកម្ពុជា (រដ្ឋធម្មនុញ្ញមាត្រា ១១ថ្មី និងមាត្រា ១២ថ្មី)។ នេះជាការធានាស្ថិរភាព និងនិរន្តរភាពរបស់រដ្ឋ។

ខ-ប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ នៃព្រឹទ្ធសភាជាសមាសភាព នៃក្រុមប្រឹក្សារាជសម្បត្តិ (រដ្ឋធម្មនុញ្ញ មាត្រា ១៣ថ្មី)។

គ-នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈ ជាក់ប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា ប្រធាន-ព្រឹទ្ធសភា (រដ្ឋធម្មនុញ្ញមាត្រា ២២ ថ្មី)។

ឃ-ព្រះមហាក្សត្រទ្រង់ប្រកាសសង្គ្រាម ក្រោយការអនុម័តរបស់រដ្ឋសភា ព្រឹទ្ធសភា (រដ្ឋធម្មនុញ្ញ មាត្រា ២៤ថ្មី)។

ង-ព្រឹទ្ធសភាមានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល (រដ្ឋធម្មនុញ្ញមាត្រា ១១២ថ្មី)។ នេះជាការធានាប្រក្រតីភាព នៃជីវភាពរបស់រដ្ឋ ដើម្បីចៀសវាងវិបត្តិតូច និងធំទាំងឡាយ។

ច-ការស្នើពិនិត្យធម្មនុញ្ញភាពនៃច្បាប់ :

ប្រធានព្រឹទ្ធសភា ឬ សមាជិកព្រឹទ្ធសភា ចំនួនមួយភាគបួន អាចបញ្ជូនច្បាប់ដែលរដ្ឋសភា បានអនុម័តទៅឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងច្បាប់នោះត្រូវប្រកាសឱ្យប្រើ (រដ្ឋធម្មនុញ្ញមាត្រា ១៤០ថ្មី)។

ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឱ្យប្រើ ប្រធានព្រឹទ្ធសភា ឬ សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន អាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យពីធម្មនុញ្ញភាពនៃច្បាប់នោះ (រដ្ឋធម្មនុញ្ញ មាត្រា ១៤១ ថ្មី)។

៤. នីតិវិធីពិនិត្យ និងឱ្យយោបល់លើអត្ថបទច្បាប់ ឬបញ្ហានានា

បញ្ជីតជាមូលដ្ឋាន :

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- សេចក្តីសំរេចលេខ ០៤៩ /០០៤/២០០២ កបធ-ច ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០២ របស់ក្រុមប្រឹក្សា-ធម្មនុញ្ញ
- បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាដែលប្រកាសឱ្យប្រើតាមសេចក្តីសម្រេចលេខ ០៧៥/០៦០៦/ពស/សរ ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០៦ របស់ប្រធានព្រឹទ្ធសភា និង
- វិសោធនកម្ម បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ដែលប្រកាសឱ្យប្រើតាមសេចក្តីសម្រេចលេខ : ០៨៥/០៧០៦/ពស/សរ ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៦ របស់ប្រធានព្រឹទ្ធសភា

ការពិភាក្សា និងឱ្យយោបល់ត្រូវធ្វើតាមលំដាប់លំដោយដូចតទៅ :

ក. ការដាក់ជូនអត្ថបទច្បាប់ ឬបញ្ហានានា

អត្ថបទច្បាប់ ឬបញ្ហានានា ដែលរដ្ឋសភាបានអនុម័តលើកដំបូងរួចហើយ ត្រូវដាក់ជូនមកគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា។

អត្ថបទច្បាប់ ត្រូវធ្វើជាលាយលក្ខណ៍អក្សរចែកជាមាត្រាហើយមានសេចក្តីថ្លែងហេតុភ្ជាប់មកជាមួយ។

គណៈកម្មាធិការអចិន្ត្រៃយ៍ពិនិត្យ ហើយសម្រេចប្រគល់អត្ថបទច្បាប់នោះឱ្យគណៈកម្មការជំនាញណាមួយក្នុងចំណោមគណៈកម្មការជំនាញទាំង៩ របស់ព្រឹទ្ធសភា។

ខ. ការពិនិត្យក្នុងគណៈកម្មការជំនាញ

គណៈកម្មការជំនាញបន្ទាប់ពីបានទទួលអត្ថបទច្បាប់ ឬបញ្ហានានាពីគណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវសុំយោបល់ពីសមាជិកព្រឹទ្ធសភា (យល់ព្រម កែសម្រួល បដិសេធ) លើអត្ថបទច្បាប់ ឬបញ្ហានានា ដែលសមាជិកព្រឹទ្ធសភាម្នាក់ៗបានទទួល។

សមាជិកព្រឹទ្ធសភា ត្រូវជូនយោបល់ ០៣ ថ្ងៃយ៉ាងយូរមុនពិនិត្យអត្ថបទច្បាប់ ឬបញ្ហានានា ដែលគណៈកម្មការជំនាញចាត់ទុកជាច្បាប់ធម្មតា ឬ ០១ថ្ងៃយ៉ាងយូរមុនពិនិត្យអត្ថបទច្បាប់ ឬបញ្ហានានា ដែលគណៈកម្មការជំនាញចាត់ទុកជាការប្រញាប់។ គណៈកម្មការជំនាញមានសិទ្ធិសម្រេចចំពោះយោបល់នេះ។

គណៈកម្មការជំនាញ ត្រូវបើកកិច្ចប្រជុំពិនិត្យ ពិភាក្សាក្នុងផ្ទៃក្នុងគណៈកម្មការ ឬប្រជុំអន្តរគណៈកម្មការ ដោយមានការចូលរួមបំភ្លឺពីម្ចាស់សំណើសុំកែសម្រួល ឬម្ចាស់អត្ថបទច្បាប់ ឬបញ្ហានានា ឬពីក្រុមជំនាញ ឬពិគ្រោះយោបល់ជាសាធារណៈជាមួយសង្គមស៊ីវិល ឬមជ្ឈដ្ឋានសង្គមផ្សេងៗបើយល់ថាចាំបាច់ ។

ការពិនិត្យ ពិភាក្សាត្រូវធ្វើដូចតទៅ :

ក-ពិនិត្យ និងពិភាក្សាលើសំណើសុំចាត់ទុកជាការប្រញាប់នៃអត្ថបទច្បាប់ ឬបញ្ហានានា បើមាន។

ខ-ពិនិត្យ និងពិភាក្សាលើសំណើសុំកែសម្រួល បើមាន។

គ-ពិនិត្យ និងពិភាក្សាលើខ្លឹមសារនៃអត្ថបទច្បាប់ ឬបញ្ហានានា។

ឃ-នាំយកយោបល់ និងជំហររបស់គណៈកម្មការ លើលទ្ធភាពណាមួយក្នុងចំណោមលទ្ធភាពដូចខាងក្រោម :

- ស្នើព្រឹទ្ធសភាយល់ព្រមទទួលយកសំណើសុំចាត់ទុកជាការប្រញាប់ ឬមិនចាត់ទុកជាការប្រញាប់នៃអត្ថបទច្បាប់ ឬបញ្ហានានា បើមាន
- ឬស្នើព្រឹទ្ធសភាយល់ព្រមទទួលយកអត្ថបទច្បាប់ ឬបញ្ហានានាទាំងមូល ដោយឥតកែប្រែ
- ឬស្នើព្រឹទ្ធសភាឱ្យពិចារណាកែសម្រួល ឬមិនទទួលយកការកែសម្រួល
- ឬស្នើព្រឹទ្ធសភាបដិសេធអត្ថបទច្បាប់ ឬបញ្ហានានាជាអសារបង់ ។

គ. ការពិនិត្យឱ្យយោបល់លើអត្ថបទច្បាប់ ឬបញ្ហានានាក្នុងពេលប្រជុំពេញអង្គ

ការពិនិត្យឱ្យយោបល់ ធ្វើឡើងលើខ្លឹមសារទូទៅ និងលើខ្លឹមសារទាំងមូលតែម្តង នៃអត្ថបទច្បាប់ ឬបញ្ហានានា ដែលរដ្ឋសភាបញ្ជូនមកព្រឹទ្ធសភា តាមនីតិវិធីដូចខាងក្រោម:

ជាទូទៅការពិនិត្យឱ្យយោបល់ ផ្តើមឡើងដោយការបង្ហាញរបាយការណ៍របស់គណៈកម្មការជំនាញ ការបកស្រាយបំភ្លឺរបស់តំណាងរាជរដ្ឋាភិបាល ម្ចាស់អត្ថបទច្បាប់ ឬបញ្ហានានា។

សមាជិកព្រឹទ្ធសភា អាចមានមតិ យោបល់ភ្លាមបន្ទាប់ពីតំណាងគណៈកម្មការជំនាញ ឬ តំណាងរាជ-រដ្ឋាភិបាល ឬម្ចាស់អត្ថបទច្បាប់ ឬបញ្ហានានា ក្នុងចិរវេលាមិនឱ្យលើសពីការកំណត់ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា។

តំណាងរាជរដ្ឋាភិបាល ឬម្ចាស់អត្ថបទច្បាប់ ឬបញ្ហានានា ឬគណៈកម្មការជំនាញ អាចបំភ្លឺបកស្រាយចំពោះមតិយោបល់របស់សមាជិកព្រឹទ្ធសភា ដែលបានលើកឡើង។

ក្នុងពេលកំពុងពិនិត្យ ឱ្យយោបល់ មតិសុំកែសម្រួល ឬមតិបដិសេធអត្ថបទច្បាប់ ឬបញ្ហានានា អង្គប្រជុំត្រូវពិនិត្យ និងអនុម័តភ្លាមថា ទទួល ឬមិនទទួលមតិយោបល់ខាងលើ បន្ទាប់ពីការបកស្រាយបំភ្លឺ ពន្យល់ពីតំណាងរាជរដ្ឋាភិបាល ឬម្ចាស់អត្ថបទច្បាប់ ឬបញ្ហានានា និងតំណាងគណៈកម្មការជំនាញ ព្រមទាំងមតិយោបល់សមាជិកព្រឹទ្ធសភារួចមក។

នៅកិច្ចបញ្ចប់ដំណាក់កាលពិនិត្យ ឱ្យយោបល់ :

-អង្គប្រជុំពិនិត្យ ឱ្យយោបល់យល់ព្រមលើអត្ថបទច្បាប់ ឬបញ្ហានានា ដោយឥតកែប្រែប្រសិនជាគ្មានមតិយោបល់កែសម្រួល និងបដិសេធ។

-បើអង្គប្រជុំទទួលយកយោបល់សុំកែសម្រួលអត្ថបទច្បាប់ ឬបញ្ហានានា ព្រឹទ្ធសភា ត្រូវបញ្ជូនយោបល់ខាងលើនេះភ្លាមទៅរដ្ឋសភា ដើម្បីពិចារណា។

-បើអង្គប្រជុំទទួលយកយោបល់បដិសេធ ក្នុងករណីនេះអង្គប្រជុំត្រូវផ្អាក ហើយជូនព័ត៌មាននេះទៅរដ្ឋសភា។

(ជំពូកទី៩ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា)

ឃ. ការបង្វិលទៅបង្វិលមកវាងព្រឹទ្ធសភា និងរដ្ឋសភា

ក្នុងករណីព្រឹទ្ធសភាមិនឯកភាពតាមការអនុម័តដំបូងរបស់រដ្ឋសភា ព្រឹទ្ធសភាបង្វិលទៅរដ្ឋសភាជាលើកទី ១ ស្នើសុំកែប្រែ។ រដ្ឋសភាបានទទួលហើយ ប៉ុន្តែមិនឯកភាពទាំងស្រុង ឬដោយអន្លើនឹងសំណើកែប្រែរបស់ព្រឹទ្ធសភាក៏បង្វិលមកព្រឹទ្ធសភាវិញសុំឱ្យពិចារណាជាថ្មី។ ព្រឹទ្ធសភាពិចារណាជាថ្មី ហើយក៏បង្វិលទៅរដ្ឋសភាវិញដោយបញ្ជាក់យោបល់របស់ខ្លួនម្តងទៀត។ បើរដ្ឋសភាមិនទាន់ឯកភាពតាមព្រឹទ្ធសភា ការបង្វិលទៅបង្វិលមកអាចបន្តទៅទៀតបាន ជាធម្មតាក្នុងរយៈពេល ១ខែសម្រេចពិនិត្យច្បាប់ផ្សេងៗ ក្រៅពីច្បាប់ថវិកាជាតិ និងហិរញ្ញវត្ថុ ដែលត្រូវកំណត់ត្រឹម ១០ថ្ងៃ។ បើជាការប្រញាប់ រយៈពេលនេះត្រូវបន្ថយមកត្រឹមតែ២ថ្ងៃប៉ុណ្ណោះ។ រយៈពេល នៃការបង្វិលនេះ ត្រូវគិតពីថ្ងៃបង្វិលលើកទី១ របស់ព្រឹទ្ធសភា។


ង. ការប្រកាសឱ្យប្រើច្បាប់

ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យឱ្យយោបល់ចប់សព្វគ្រប់រួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេលដប់ថ្ងៃគត់ក្រោយពីថ្ងៃប្រកាសឱ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេលម្ភៃថ្ងៃគត់ក្រោយពីថ្ងៃប្រកាសឱ្យប្រើ។ ប៉ុន្តែបើច្បាប់នេះបានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេសក្រោយថ្ងៃប្រកាសឱ្យប្រើ។

ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចុះក្នុងរាជកិច្ច និងផ្សព្វផ្សាយនៅទូទាំងប្រទេសឱ្យទាន់តាមពេលកំណត់ខាងលើ។

គំនូសបំព្រួញ នីតិវិធីនៃការពិនិត្យ និងអនុម័តច្បាប់

រូបទី១



កំណត់សំគាល់ : ដំណើរនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ :

(១). រវាងស្ថាប័នរាជរដ្ឋាភិបាល

(២). ដំណើរការក្នុងសភានីមួយៗ

(៣). ការបង្វិលទៅមករវាងសភាទាំងពីរ

៥. គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

គណៈកម្មាធិការអចិន្ត្រៃយ៍មាន :

- ប្រធានព្រឹទ្ធសភា
- អនុប្រធានទាំង២ របស់ព្រឹទ្ធសភា
- ប្រធានគណៈកម្មការជំនាញទាំង៩ របស់ព្រឹទ្ធសភា។

ប្រធានព្រឹទ្ធសភា ជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភា។

គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាមានភារកិច្ចដូចតទៅ :

ក-ចាត់ចែងការងាររបស់ព្រឹទ្ធសភាក្នុងចន្លោះសម័យប្រជុំព្រឹទ្ធសភា។

ខ-រៀបចំរបៀបវារៈ នៃពេលប្រជុំព្រឹទ្ធសភានីមួយៗ។

គ-រៀបចំសមាសភាពលេខាធិការ ២រូប សម្រាប់សម័យប្រជុំបន្ទាប់ពីវិស្សមកាល ដើម្បីដាក់ជូនអង្គប្រជុំអនុម័ត។

ឃ-ធានាការប្រព្រឹត្តទៅ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

ង-ធានាការប្រព្រឹត្តទៅ នៃក្រុមមិត្តភាព ឬក្រុមទទួលបន្ទុកការងារទំនាក់ទំនងអន្តរសភាតំបន់ និងអន្តរជាតិផ្សេងៗ។

ច-ធានាគ្រប់គ្រង និងការចំណាយថវិកាព្រឹទ្ធសភាឱ្យប្រព្រឹត្តទៅបានត្រឹមត្រូវតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ។

ឆ-ធានាក្នុងការផ្តល់គ្រឿងឥស្សរិយសជូនសមាជិកព្រឹទ្ធសភា។

ជ-ធានាការអនុវត្តវិន័យក្នុងព្រឹទ្ធសភា។

ឈ-លើកជូនព្រឹទ្ធសភាពិនិត្យ និងសម្រេចលើការផ្អាកការឃុំខ្លួន ការចោទប្រកាន់សមាជិកព្រឹទ្ធសភាណាមួយ។

ដ- លើកជូនព្រឹទ្ធសភាពិនិត្យ និងសម្រេចអំពីការព្យួរអភ័យឯកសិទ្ធិសភា ការប្រគល់ជូនវិញនូវអភ័យ-ឯកសិទ្ធិសភា ការបោះបង់ចោលការងារ វិសមិតភាព និងការប្រាសចាកសមាជិកភាពព្រឹទ្ធសភា។

៦. តួនាទី ភារកិច្ចរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា នីតិកាលទី២ (២០០៦-២០១២)

ក-ប្រធានព្រឹទ្ធសភា មានភារកិច្ចដូចតទៅ :

-ទទួលខុសត្រូវរួមលើការងារដឹកនាំ និងការប្រព្រឹត្តទៅនៃស្ថាប័នព្រឹទ្ធសភា គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការជំនាញទាំង៩ និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-តំណាងព្រឹទ្ធសភាក្នុងការទាក់ទងជាមួយព្រះមហាក្សត្រ រដ្ឋសភា រាជរដ្ឋាភិបាល និងអាជ្ញាធរសាធារណៈ

-តំណាងព្រឹទ្ធសភាក្នុងទំនាក់ទំនងអន្តរជាតិ។

ខ-អនុប្រធានទី ១ព្រឹទ្ធសភា មានភារកិច្ចដូចតទៅ :

- ជួយធ្វើការប្រធានលើការងារទំនាក់ទំនងអន្តរជាតិរបស់ព្រឹទ្ធសភា :

-តាមដាន និងដឹកនាំការងារពាក់ព័ន្ធដល់ក្រុមមិត្តភាពរបស់ព្រឹទ្ធសភា និងទំនាក់ទំនងរវាងព្រឹទ្ធសភាជាមួយសភា នៃប្រទេសជាមិត្ត

-តាមដាន និងដឹកនាំការងារពាក់ព័ន្ធដល់កិច្ចសហប្រតិបត្តិការរបស់ព្រឹទ្ធសភាក្នុងរង្វង់អង្គការអន្តរសភាអាស៊ាន (AIPO) សហភាពអន្តរសភា(IPU) សមាគមសភា នៃប្រទេសប្រើភាសាបារាំង (APF) និងអង្គការអន្តរជាតិផ្សេងទៀត

-ចាត់ចែងការរៀបចំសមាសភាពគណៈប្រតិភូព្រឹទ្ធសភា ទៅបំពេញបេសកកម្មនៅក្រៅប្រទេស (ទស្សនកិច្ចមិត្តភាពជាផ្លូវការ ទស្សនកិច្ចសិក្សា ការចូលរួមសន្និសីទ សិក្ខាសាលា ឬវេទិកាតំបន់ និងអន្តរជាតិ)

-តាមដាន និងដឹកនាំការងារពាក់ព័ន្ធដល់កិច្ចសហប្រតិបត្តិការរវាងព្រឹទ្ធសភាជាមួយនឹងដៃគូអន្តរជាតិ : កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) មូលនិធិខុនរ៉ាដ(KAF) គំរោងគាំទ្រនីតិប្បញ្ញត្តិកម្ពុជា-កាណាដា (CCLSP)។

- ជួយបំពេញកិច្ចការផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធាន។

គ-អនុប្រធានទី២ ព្រឹទ្ធសភា មានភារកិច្ចដូចតទៅ :

.ជួយធ្វើការប្រធានលើការងារប្រចាំថ្ងៃ ផ្ទៃក្នុងព្រឹទ្ធសភាខាងរដ្ឋបាល នីតិកម្ម និងទំនាក់ទំនងសាធារណៈ:

-តាមដានការប្រព្រឹត្តទៅ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ចាត់ចែងការងាររដ្ឋបាល នីតិកម្ម ទំនាក់ទំនងសាធារណៈរបស់ព្រឹទ្ធសភា ព្រមទាំងសុវត្ថិភាពសណ្តាប់-ធ្នាប់ក្នុងព្រឹទ្ធសភា

-តាមដាន សម្របសម្រួលការងារ និងបេសកកម្មក្នុងប្រទេសរបស់គណៈកម្មការជំនាញ និងសមាជិកព្រឹទ្ធសភា

-ចូលរួមរៀបចំប្រតិទិនការងារ ការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំពេញអង្គព្រឹទ្ធសភា

-ចាត់ចែងការឆ្លើយឆ្លង និងបញ្ជូនលិខិតស្នាមផ្ទៃក្នុងព្រឹទ្ធសភា និងទំនាក់ទំនងទៅខាងក្រៅស្ថាប័ន។

ជួយបំពេញកិច្ចការផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធាន។

យោង : សេចក្តីសម្រេចស្តីពី ការបែងចែងភារកិច្ចថ្នាក់ដឹកនាំព្រឹទ្ធសភា នីតិកាលទី២ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៦

៧. បញ្ជីរាយនាម សមាជិកា សមាជិកព្រឹទ្ធសភានីតិកាលទី២ (២០០៦-២០១២)

តាមលំដាប់អក្ខរក្រមខ្មែរ

~~~~~~~~~~~~~~~

ល.រ	គោត្តនាម-នាម	ភេទ	ថ្ងៃ.ខែ.ឆ្នាំកំណើត	ប្រភព
១	ឯកឧត្តម កង ចន្ទ	ប្រុស	០២/០៦/១៩៣០	
២	ឯកឧត្តម កុក អាន	ប្រុស	០៧/០៧/១៩៥៤	
៣	លោកជំទាវ ខួត ឥងផ្កា	ស្រី	០៨/១០/១៩៥២	
៤	ឯកឧត្តម គង់ គាំ	ប្រុស	០៦/០៤/១៩៤១	
៥	ឯកឧត្តម គង់ សារាជ	ប្រុស	២២/០៨/១៩៤៧	
៦	ឯកឧត្តម គីម ណារិទ	ប្រុស	២៨/០៥/១៩៤៥	
៧	ឯកឧត្តម ចាន់ តិន	ប្រុស	១២/០៤/១៩៣៨	
៨	ឯកឧត្តម ឆាត់ ល្បើម	ប្រុស	១០/០៨/១៩៣៦	
៩	សម្តេច ជា ស៊ីម	ប្រុស	១៥/១១/១៩៣២	
១០	ឯកឧត្តម ជា គីម	ប្រុស	១៥/១០/១៩៥៧	
១១	ឯកឧត្តម ជា សុន	ប្រុស	០២/០២/១៩៣៩	
១២	ឯកឧត្តម ជិយ សាផុន	ប្រុស	១០/១០/១៩៣០	
១៣	ឯកឧត្តម ជា ជេដ្ឋ	ប្រុស	១៣/០១/១៩៤៨	
១៤	ឯកឧត្តម ឈា ចាំង	ប្រុស	១៥/១១/១៩៣៥	
១៥	ឯកឧត្តម ឈិត គីមយាត	ប្រុស	០៨/០៦/១៩៤៧	
១៦	លោកជំទាវ ឈូក ឈឹម	ស្រី	១០/១០/១៩៥៤	
១៧	ឯកឧត្តម ឈឹម សាខន	ប្រុស	០២/០៣/១៩៥៩	
១៨	ឯកឧត្តម តូច សាក់	ប្រុស	១២/០៤/១៩៤៣	
១៩	ឯកឧត្តម ថុច ចន់	ប្រុស	០៦/០៨/១៩៤១	
២០	ឯកឧត្តម ទិត រាម	ប្រុស	០៧/០២/១៩៤៨	
២១	ឯកឧត្តម ទេព ចន	ប្រុស	០១/០១/១៩៤៧	
២២	លោកជំទាវ ទី ប៊ូរ៉ាស៊ី	ស្រី	០១/០៨/១៩៣៩	
២៣	ឯកឧត្តម ធ្នាំ ប៊ុនស្រុន	ប្រុស	០៣/១២/១៩៤២	
២៤	សម្តេចព្រះបុត្រីវ្ងះវ្ងៀម នរោត្តម បុប្ផាទេវី	ស្រី	០៨/០១/១៩៤៣	
~~~~~~~~~~~~~~~

២៥	ឯកឧត្តម	ម៉ែន	ឆាត់	ប្រុស	០១/០១/១៩៤៩	
២៦	ឯកឧត្តម	ប៊ុក	កុសល	ប្រុស	០៤/០១/១៩៥៣	
២៧	ឯកឧត្តម	ឆោ	ប៊ុនស្រ៊ី	ប្រុស	០១/១០/១៩៤៧	
២៨	លោកជំទាវ	ព្រុំ	ស៊ាត	ស្រី	១១/០១/១៩៤៤	
២៩	លោកជំទាវ	ពុំ	ស៊ីចាន់	ស្រី	០១/១១/១៩៤៧	
៣០	ឯកឧត្តម	ពុត	ជួប	ប្រុស	០៥/០៤/១៩៤៩	
៣១	ឯកឧត្តម	ពុធ	ខូវ	ប្រុស	០១/០៥/១៩៤៩	
៣២	ឯកឧត្តម	ពៅ	សិទ្ធិ	ប្រុស	០៤/០១/១៩៥៥	
៣៣	លោកជំទាវ	ម៉ែន	ម៉ាលី	ស្រី	០១/១០/១៩៤៥	
៣៤	លោកជំទាវ	មាន	សំអាន	ស្រី	១៦/០៦/១៩៥៦	
៣៥	ឯកឧត្តម	ម៉ែន	សារុន	ប្រុស	១៩/០៨/១៩៤៦	
៣៦	ឯកឧត្តម	ម៉ុច	ឫទ្ធី	ប្រុស	១១/០៧/១៩៥៤	
៣៧	ឯកឧត្តម	យ៉ង់	សែម	ប្រុស	០១/១២/១៩៤៣	
៣៨	ឯកឧត្តម	រស់	ស្រេង	ប្រុស	១៥/០៣/១៩៣៩	
៣៩	ឯកឧត្តម	ឈឺ	ឃុនថាត់	ប្រុស	០៧/០១/១៩៥៨	
៤០	ឯកឧត្តម	ទ៉ាន់	ម៉ាត់	ប្រុស	០១/០១/១៩៤៨	
៤១	ឯកឧត្តម	ទ៉ាន់	ស៊ុនវ៉ឺន	ប្រុស	១៥/០១/១៩៥២	
៤២	ឯកឧត្តម	សេក	សំអឿត	ប្រុស	១៥/០៦/១៩៣០	
៤៣	ឯកឧត្តម	សាប៊ូ	ឆាចា	ប្រុស	១៦/០១/១៩៤៣	
៤៤	ឯកឧត្តម	ប៉ឿយ	កើក	ប្រុស	១០/០៤/១៩៣៩	
៤៥	ឯកឧត្តម	ស៊ឹម	កា	ប្រុស	១៩/០៤/១៩៤៣	
៤៦	សម្តេច	ស៊ីសុវត្ថិ	ជីវ័ន្តមុនីវង្ស	ប្រុស	០១/០២/១៩៣៦	
៤៧	ឯកឧត្តម	ស៊ើយ	កែវ	ប្រុស	០៣/០៦/១៩៤៣	
៤៨	ឯកឧត្តម	សោម	សុផា	ប្រុស	១៥/១០/១៩៣៧	
៤៩	ឯកឧត្តម	សួន	ឈន់	ប្រុស	១៧/០៤/១៩៤៣	
៥០	ឯកឧត្តម	ស៊ុ	គង់ទ្រីវ	ប្រុស	០៨/០៨ /១៩៤៧	
៥១	ឯកឧត្តម	ហុច	ទូហាយ	ប្រុស	២៧/១០/១៩៣៩	
៥២	លោកជំទាវ	ឡាក់	អូន	ស្រី	២១/១២/១៩៤៥	
៥៣	ឯកឧត្តម	ឡាវ	ម៉េងឃីន	ប្រុស	០១/០១/១៩៤៤	

៥៤	ឯកឡត្តម	ឡាយ	អ៊ុតិសិទ្ធិ	ប្រុស	០៥/០១/១៩៤៨	
៥៥	ឯកឡត្តម	អៀវ	បណ្ណាការ	ប្រុស	២១/០២/១៩៣១	
៥៦	ឯកឡត្តម	អ៊ុក	គង់	ប្រុស	២០/០៥/១៩៤៩	
៥៧	ឯកឡត្តម	អ៊ុក	ប៊ុនឈ្បឿន	ប្រុស	០៥/០៣/១៩៤៣	
៥៨	ឯកឡត្តម	អ៊ុំ	សារិទ្ធ	ប្រុស	០២/០៤/១៩៤៧	
៥៩	ឯកឡត្តម	អ៊ុំ	ម៉ាន្ធូរិន	ប្រុស	០៤/០៣/១៩២៤	
៦០	ឯកឡត្តម	អ៊ុច	ហួត	ប្រុស	០១/០១/១៩៤៧	
៦១	ឯកឡត្តម	អ៊ុច	ទី	ប្រុស	៣០/០៦/១៩៤៩	

៨. បញ្ជីរាយនាម សមាជិកា សមាជិកព្រឹទ្ធសភានីតិកាលទី២ តាមលំដាប់អាយុពីខ្ពស់ មកទាប

ល.រ	គោត្តនាម-នាម	តេទ	ថ្ងៃ.ខែ.ឆ្នាំកំណើត	ប្រតព
១	ឯកឧត្តម អ៊ុំ ម៉ាន្នីរ័ន	ប្រុស	០៣/០៤/១៩២៤	
២	ឯកឧត្តម សេក សំអឿត	ប្រុស	១៥/០៦/១៩៣០	
៣	ឯកឧត្តម ជិយ សាផុន	ប្រុស	១០/១០/១៩៣០	
៤	ឯកឧត្តម អឿវ បណ្ណាការ	ប្រុស	០២/២១/១៩៣១	
៥	ឯកឧត្តម កង ចន្ទ	ប្រុស	០២/០៦/១៩៣២	
៦	សម្តេច ជា ស៊ីម	ប្រុស	១៥/១១/១៩៣២	
៧	ឯកឧត្តម ឈរ ថាំង	ប្រុស	១៥/១១/១៩៣៥	
៨	សម្តេច ស៊ីសុវត្ថិ ជីវ័ន្តមុនីវង្ស	ប្រុស	០១/០២/១៩៣៦	
៩	ឯកឧត្តម ឆាត់ ឈ្មឹម	ប្រុស	១០/០៨/១៩៣៦	
១០	ឯកឧត្តម សោម សុផា	ប្រុស	១៥/១០/១៩៣៧	
១១	ឯកឧត្តម ចាន់ គិន	ប្រុស	១២/០៤/១៩៣៨	
១២	ឯកឧត្តម ជា សុន	ប្រុស	០២/០២/១៩៣៩	
១៣	ឯកឧត្តម រស់ ស្រេង	ប្រុស	១៥/០៣/១៩៣៩	
១៤	ឯកឧត្តម ប៉ើយ កើក	ប្រុស	១០/០៤/១៩៣៩	
១៥	លោកជំទាវ ធី ប៊ូរ៉ាស៊ី	ស្រី	០១/០៨/១៩៣៩	
១៦	ឯកឧត្តម ហុង ឌូហាយ	ប្រុស	២៧/១០/១៩៣៩	
១៧	ឯកឧត្តម គង់ គាំ	ប្រុស	០៦/០៤/១៩៤១	
១៨	ឯកឧត្តម ថុច ចន់	ប្រុស	០៦/០៨/១៩៤១	
១៩	ឯកឧត្តម ឆ្លាំ ប៊ុនស្រុន	ប្រុ	០៣/១២/១៩៤២	
២០	សម្តេចរាជបុត្រីព្រះរៀម នរោត្តម បុប្ផាទេវី	ស្រី	០៨/០១/១៩៤៣	
២១	ឯកឧត្តម សាប៉ូ ចាចា	ប្រុស	១៦/០១/១៩៤៣	
២២	ឯកឧត្តម ឌិត រាម	ប្រុស	០៧/០២/១៩៤៣	
២៣	ឯកឧត្តម អ៊ុក ប៊ុនឈ្មឹន	ប្រុស	០៥/០៣/១៩៤៣	
២៤	ឯកឧត្តម តូច សាក់	ប្រុស	១២/០៤/១៩៤៣	
២៥	ឯកឧត្តម សួន ឈន់	ប្រុស	១៧/០៤/១៩៤៣	

២៦	ឯកឧត្តម	ស៊ើយ	កែវ	ប្រុស	០៣/០៦/១៩៤៣	
២៧	ឯកឧត្តម	យ៉ង់	សែម	ប្រុស	០១/១២/១៩៤៣	
២៨	ឯកឧត្តម	ឡាវ	ម៉េងឃីន	ប្រុស	០១/០១/១៩៤៤	
២៩	លោកជំទាវ	ព្រាំ	ស៊ីត	ស្រី	១១/០១/១៩៤៤	
៣០	ឯកឧត្តម	គីម	ណារិទ	ប្រុស	២៨/០៥/១៩៤៥	
៣១	លោកជំទាវ	ម៉ែន	ម៉ាលី	ស្រី	០១/១០/១៩៤៥	
៣២	លោកជំទាវ	ឡាក់	អូន	ស្រី	២១/១២/១៩៤៥	
៣៣	ឯកឧត្តម	ម៉ែន	សារុន	ប្រុស	១៩/០៨/១៩៤៦	
៣៤	ឯកឧត្តម	ឆេង	ចន	ប្រុស	០១/០១/១៩៤៧	
៣៥	ឯកឧត្តម	អ៊ុច	ហួត	ប្រុស	០១/០១/១៩៤៧	
៣៦	ឯកឧត្តម	អ៊ុំ	សារិន្ធ	ប្រុស	០២/០៤/១៩៤៧	
៣៧	ឯកឧត្តម	ឈិត	គីមយាត	ប្រុស	០៨/០៦/១៩៤៧	
៣៨	ឯកឧត្តម	ស៊ុ	គង់ទ្រីត	ប្រុស	០៨/០៨/១៩៤៧	
៣៩	ឯកឧត្តម	គង់	សារាជ	ប្រុស	២២/០៨/១៩៤៧	
៤០	លោកជំទាវ	ពុំ	ស៊ុចាន់	ស្រី	០១/១១/១៩៤៧	
៤១	ឯកឧត្តម	ឥន	ម៉ាត់	ប្រុស	០១/០១/១៩៤៨	
៤២	ឯកឧត្តម	ឡាយ	អ៊ុតិសិទ្ធិ	ប្រុស	០៥/០១/១៩៤៨	
៤៣	ឯកឧត្តម	ជា	ដេដ្ឋ	ប្រុស	១៣/០១/១៩៤៨	
៤៤	ឯកឧត្តម	ស៊ឹម	កា	ប្រុស	១៩/០៤/១៩៤៨	
៤៥	ឯកឧត្តម	ប៉ែង	ឃ៉ាត់	ប្រុស	០១/០១/១៩៤៩	
៤៦	ឯកឧត្តម	ពុត	ជួប	ប្រុស	០៥/០៤/១៩៤៩	
៤៧	ឯកឧត្តម	ពុធ	ខូវ	ប្រុស	០១/០៥/១៩៤៩	
៤៨	ឯកឧត្តម	អ៊ុក	គង់	ប្រុស	២០/០៥/១៩៤៩	
៤៩	ឯកឧត្តម	អ៊ុច	ឆី	ប្រុស	៣០/០៦/១៩៤៩	
៥០	ឯកឧត្តម	ឆោ	ប៊ុនស្រ៊ី	ប្រុស	០១/១០/១៩៤៩	
៥១	ឯកឧត្តម	ឥន	ស៊ីវ៉ឿន	ប្រុស	១៥/០១/១៩៥២	
៥២	លោកជំទាវ	ខ្លូត	ឧចង្កា	ស្រី	០៨/១០/១៩៥២	
៥៣	ឯកឧត្តម	ប៊ុក	កុសល	ប្រុស	០៤/០១/១៩៥៣	
៥៤	ឯកឧត្តម	កុក	អាន	ប្រុស	០៤/០១/១៩៥៣	

៥៥	ឯកឱត្តម ម៉ុច ឫទ្ធិ	ប្រុស	១១/០៧/១៩៥៤	
៥៦	លោកជំទាវ ឈូក ឈីម	ស្រី	១០/១០/១៩៥៤	
៥៧	ឯកឱត្តម ពៅ សិទ្ធិ	ប្រុស	០៤/០១/១៩៥៥	
៥៨	លោកជំទាវ មាន សំអាន	ស្រី	១៦/០៦/១៩៥៦	
៥៩	ឯកឱត្តម ជា គីម	ប្រុស	១៥/១០/១៩៥៧	
៦០	ឯកឱត្តម ណី យ៉ុងផាត់	ប្រុស	០៧/០១/១៩៥៨	
៦១	ឯកឱត្តម ឈីម សាខន	ប្រុស	០២/០៣/១៩៥៩	

៩. បញ្ជីរាយនាមសមាជិកា សមាជិកព្រឹទ្ធសភានីតិកាលទី ២ (២០០៦-២០១២)
តាមមណ្ឌលភូមិភាគ

ក. មណ្ឌលភូមិភាគ ទី ១ (ភ្នំពេញ)

អាសនៈរួម ៦	ល.រ	គោត្តនាម-នាម	ភេទ	ថ្ងៃ.ខែ.ឆ្នាំកំណើត	គណបក្ស
គណបក្សប្រជាជនកម្ពុជា ៤ អាសនៈ	១	សម្តេច ជា ស៊ីម	ប្រុស	១៥/១១/១៩៣២	
	២	ឯកឧត្តម ស៊ីម កា	ប្រុស	១៩/០៤/១៩៤៨	
	៣	ឯកឧត្តម ជា ជេដ្ឋ	ប្រុស	១៣/០១/១៩៤៨	
	៤	លោកជំទាវ ពុំ ស៊ីចាន់	ស្រី	០១/១១/១៩៤៧	
គណបក្ស សម រង្ស៊ី ១ អាសនៈ	៥	ឯកឧត្តម គង់ គាំ	ប្រុស	០៦/០៤/១៩៤១	
គណបក្ស ហ៊ុនស៊ិនប៉ិច ១ អាសនៈ	៦	ឯកឧត្តម ប៉ុក កុសល	ប្រុស	០៤/០១/១៩៥៣	

ខ. មណ្ឌលភូមិភាគ ទី ២ (ខេត្តកំពង់ចាម)

អាសនៈរួម ៨	ល.រ	គោត្តនាម-នាម	ភេទ	ថ្ងៃ.ខែ.ឆ្នាំកំណើត	គណបក្ស
គណបក្សប្រជាជនកម្ពុជា ៥ អាសនៈ	១	ឯកឧត្តម អ៊ុក ប៊ុនឈឿន	ប្រុស	០៥/០៣/១៩៤៣	
	២	ឯកឧត្តម ទិត រាម	ប្រុស	០៧/០២/១៩៤៣	
	៣	លោកជំទាវ ឈួក ឈីម	ស្រី	១០/១០/១៩៥៤	
	៤	ឯកឧត្តម ភ័ន់ ម៉ាត់	ប្រុស	០១/០១/១៩៤៨	
	៥	ឯកឧត្តម ឈិត គីមយាត	ប្រុស	០៨/០៦/១៩៤៧	
គណបក្ស សម រង្ស៊ី ១ អាសនៈ	៦	ឯកឧត្តម ភ័ន់ ស៊ីវឿន	ប្រុស	១៥/០១/១៩៥២	
គណបក្ស ហ៊ុនស៊ិនប៉ិច ២ អាសនៈ	៧	ឯកឧត្តម ពៅ សិទ្ធិ	ប្រុស	០៤/០១/១៩៥៥	
	៨	លោកជំទាវ ម៉ែន ម៉ាលី	ស្រី	០១/១០/១៩៤៥	

គ. មណ្ឌលភូមិភាគ ទី ៣ (ខេត្តកណ្តាល)

អាសនៈរួម ៥	ល.រ	គោត្តនាម-នាម	ភេទ	ថ្ងៃ.ខែ.ឆ្នាំកំណើត	គណបក្ស
គណបក្សប្រជាជនកម្ពុជា ៤ អាសនៈ	១	ឯកឧត្តម ទេព ឯន	ប្រុស	០១/០១/១៩៤៧	
	២	លោកជំទាវ ទី បូរ៉ាស៊ី	ស្រី	០១/០៨/១៩៣៩	
	៣	ឯកឧត្តម ស៊ុ គង់ទ្រីវ	ប្រុស	០៨/០៨/១៩៤៧	
	៤	ឯកឧត្តម ឡាវ ម៉េងឃីន	ប្រុស	០១/០១/១៩៤៤	
គណបក្ស ហ៊ុនស៊ុនប៉ិច ១ អាសនៈ	៥	សម្តេច ស៊ីសុវត្ថិ ជីវនមុនីវង្ស	ប្រុស	០១/០២/១៩៣៦	

ឃ. មណ្ឌលភូមិភាគ ទី៤ (ខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប ខ្នុរមានជ័យ និងក្រុងប៉ៃលិន)

អាសនៈរួម ១០	ល.រ	គោត្តនាម-នាម	ភេទ	ថ្ងៃ.ខែ.ឆ្នាំកំណើត	គណបក្ស
គណបក្សប្រជាជនកម្ពុជា ៨ អាសនៈ	១	ឯកឧត្តម សេក សំអឿត	ប្រុស	១៥/០៦/១៩៣០	
	២	ឯកឧត្តម ឈា ថាំង	ប្រុស	១៥/១១/១៩៣៥	
	៣	ឯកឧត្តម កង ចន្ទ	ប្រុស	០២/០៦/១៩៣២	
	៤	ឯកឧត្តម អ៊ុក គង់	ប្រុស	២០/០៥/១៩៤៩	
	៥	ឯកឧត្តម សួន លន់	ប្រុស	១៧/០៤/១៩៤៣	
	៦	ឯកឧត្តម ពុត ជួប	ប្រុស	០៥/០៤/១៩៤៩	
	៧	ឯកឧត្តម ឆាត់ ល្បឿម	ប្រុស	១០/០៨/១៩៣៦	
	៨	ឯកឧត្តម ហុង ទូហាយ	ប្រុស	២៧/១០/១៩៣៩	
គណបក្ស ហ៊ុនស៊ុនប៉ិច ២ អាសនៈ	៩	ឯកឧត្តម អ៊ឹង ហួត	ប្រុស	០១/០១/១៩៤៧	
	១០	ឯកឧត្តម ជា គីម	ប្រុស	១៥/១០/១៩៥៧	

១. មណ្ឌលភូមិភាគ ទី ៥ (ខេត្តតាកែវ កំពត និងព្រៃវែង)

អាសនៈរួម ៧	ល.រ	គោត្តនាម-នាម	ភេទ	ថ្ងៃ.ខែ.ឆ្នាំកំណើត	គណបក្ស
គណបក្សប្រជាជនកម្ពុជា ៦ អាសនៈ	១	ឯកឧត្តម ប៉ែង ប៉ាត់	ប្រុស	០១/០១/១៩៤៩	
	២	ឯកឧត្តម តូច សាក់	ប្រុស	១២/០៤/១៩៤៣	
	៣	ឯកឧត្តម កុក អាន	ប្រុស	០៧/០៧/១៩៥៤	
	៤	ឯកឧត្តម ពុធ ខូវ	ប្រុស	០១/០៥/១៩៤៩	
	៥	ឯកឧត្តម ម៉ុង ឫទ្ធី	ប្រុស	១១/០៧/១៩៥៤	
	៦	ឯកឧត្តម អ៊ុង ទី	ប្រុស	៣០/០៦/១៩៤៩	
គណបក្ស ហ៊ុនស៊ុនប៉ិច ១ អាសនៈ	៧	លោកជំទាវ ខួត ទងផ្កា	ស្រី	០៨/១០/១៩៥២	

២. មណ្ឌលភូមិភាគ ទី ៦ (ខេត្តព្រៃវែង និងស្វាយរៀង)

អាសនៈរួម ៧	ល.រ	គោត្តនាម-នាម	ភេទ	ថ្ងៃ.ខែ.ឆ្នាំកំណើត	គណបក្ស
គណបក្សប្រជាជនកម្ពុជា ៦ អាសនៈ	១	លោកជំទាវ មាន សំអាន	ស្រី	១៦/០៦/១៩៥៦	
	២	ឯកឧត្តម ចាន់ ភិន	ប្រុស	១២/០៤/១៩៣៨	
	៣	ឯកឧត្តម ម៉ែន សារុន	ប្រុស	១៩/០៨/១៩៥៦	
	៤	ឯកឧត្តម ជ័យ សាផុន	ប្រុស	១០/១០/១៩៣០	
	៥	ឯកឧត្តម ជា សុន	ប្រុស	០២/០២/១៩៣៩	
	៦	ឯកឧត្តម គីម ណាំង	ប្រុស	២៨/០៥/១៩៤៥	
គណបក្ស ហ៊ុនស៊ុនប៉ិច ១ អាសនៈ	៧	ឯកឧត្តម ឈឹម សាខន	ប្រុស	០២/០៣/១៩៥៩	

៧. មណ្ឌលភូមិភាគ ទី៧ (ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ពោធិសាត់ កោះកុង និងក្រុងព្រះសីហនុ)

អាសនៈរួម ៨	ល.រ	គោត្តនាម-នាម	ភេទ	ថ្ងៃ.ខែ.ឆ្នាំកំណើត	គណបក្ស
គណបក្សប្រជាជនកម្ពុជា ៧ អាសនៈ	១	លោកជំទាវ ឡាក់ អូន	ស្រី	២១/១២/១៩៤៥	
	២	ឯកឧត្តម អ៊ុំ សារិទ្ធ	ប្រុស	០២/០៤/១៩៤៧	
	៣	ឯកឧត្តម រស់ ស្រេង	ប្រុស	១៥/០៣/១៩៣៩	
	៤	ឯកឧត្តម ថុង ចន់	ប្រុស	០៦/០៨/១៩៤១	
	៥	ឯកឧត្តម គង់ សារាជ	ប្រុស	២២/០៨/១៩៤៧	
	៦	ឯកឧត្តម លី យ៉ុងផាត់	ប្រុស	០៧/០១/១៩៥៨	
	៧	ឯកឧត្តម ឡាយ អ៊ីពិសិទ្ធិ	ប្រុស	០៥/០១/១៩៤៨	
គណបក្ស ហ៊្វុនស៊ិនប៉ិច ១ អាសនៈ	៨	ឯកឧត្តម ធ្នាំ ប៊ុនស្រុន	ប្រុស	០៣/១២/១៩៤២	


៨. មណ្ឌលភូមិភាគ ទី ៨ (ខេត្តកំពង់ធំ ព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនគីរី និងមណ្ឌលគីរី)

អាសនៈរួម ៦	ល.រ	គោត្តនាម-នាម	ភេទ	ថ្ងៃ.ខែ.ឆ្នាំកំណើត	គណបក្ស
គណបក្សប្រជាជនកម្ពុជា ៥ អាសនៈ	១	ឯកឧត្តម យ៉ង់ សែម	ប្រុស	០១/១២/១៩៤៣	
	២	ឯកឧត្តម ស៊ើយ កែវ	ប្រុស	០៣/០៦/១៩៤៣	
	៣	ឯកឧត្តម សោម សុផា	ប្រុស	១៥/១០/១៩៣៧	
	៤	ឯកឧត្តម ប្បើយ កើក	ប្រុស	១០/០៤/១៩៣៩	
	៥	លោកជំទាវ ព្រំ សិត	ស្រី	១១/០១/១៩៤៤	
គណបក្ស ហ៊្វុនស៊ិនប៉ិច ១ អាសនៈ	៦	ឯកឧត្តម ប៉ោ ប៊ុនស្រ៊ី	ប្រុស	០១/១០/១៩៤៩	

១០. ស្ថិតិអំពីសមាជិកា សមាជិកព្រឹទ្ធសភានីតិកាលទី ២ (២០០៦-២០១២)


ក. តាមភេទ

បុរស	ស្ត្រី
៥២ រូប	០៩ រូប




ខ. តាមអាយុ

៤០-៥០	៥១-៦០	៦១-៧០	៧១-៨៥
៤ រូប	២៤ រូប	២៦ រូប	៧ រូប



ក. តារាងប្រភេទ

គណបក្សប្រជាជនកម្ពុជា	គណបក្សហ៊្វុនស៊ិនប៉ិច	គណបក្សសម រង្ស៊ី	តំណាងរដ្ឋសភា	តំណាងព្រះមហាក្សត្រ
៤៥ រូប	១០ រូប	២ រូប	២ រូប	២ រូប



១១. បញ្ជីរាយនាមសមាជិកា-សមាជិកព្រឹទ្ធសភា នីតិកាលទី ២ តាមគណបក្ស

១. គណបក្សប្រជាជនកម្ពុជា

ល.រ	គោត្តនាម-នាម			តេទ	គណបក្ស
១	ឯកឧត្តម	កង	ចន្ទ	ប្រុស	
២	ឯកឧត្តម	កុក	អាន	ប្រុស	
៣	ឯកឧត្តម	គង់	សារាជ	ប្រុស	
៤	ឯកឧត្តម	គីម	ណារិទ	ប្រុស	
៥	ឯកឧត្តម	ចាន់	តិន	ប្រុស	
៦	ឯកឧត្តម	ឆាត់	ឈៀម	ប្រុស	
៧	សម្តេច	ជា	ស៊ីម	ប្រុស	
៨	ឯកឧត្តម	ជា	សុន	ប្រុស	
៩	ឯកឧត្តម	ជិយ	សាផុន	ប្រុស	
១០	ឯកឧត្តម	ជា	ជេដ្ឋ	ប្រុស	
១១	ឯកឧត្តម	ឈា	ចាំង	ប្រុស	
១២	ឯកឧត្តម	ឈិត	គីមយាត	ប្រុស	
១៣	លោកជំទាវ	ឈូក	ឈីម	ស្រី	
១៤	ឯកឧត្តម	តូច	សាក់	ប្រុស	
១៥	ឯកឧត្តម	ថុច	ចន់	ប្រុស	
១៦	ឯកឧត្តម	ទិត	រាម	ប្រុស	
១៧	ឯកឧត្តម	ឆេត	ចន	ប្រុស	
១៨	លោកជំទាវ	ឌី	ឫរ៉ាស៊ី	ស្រី	
១៩	ឯកឧត្តម	ប៉ែន	ប៉ាត់	ប្រុស	
២០	លោកជំទាវ	ព្រាំ	ស៊ីត	ស្រី	
២១	លោកជំទាវ	ពុំ	ស៊ីចាន់	ស្រី	
២២	ឯកឧត្តម	ពុត	ជួប	ប្រុស	
២៣	ឯកឧត្តម	ពុធ	ខូវ	ប្រុស	
២៤	លោកជំទាវ	មាន	សំអាន	ស្រី	

២៥	ឯកឧត្តម ម៉ែន សារុន	ប្រុស	
២៦	ឯកឧត្តម ម៉ុង ឫទ្ធី	ប្រុស	
២៧	ឯកឧត្តម យ៉ង់ សែម	ប្រុស	
២៨	ឯកឧត្តម រស់ ស្រេង	ប្រុស	
២៩	ឯកឧត្តម លី យ៉ង់ដាត់	ប្រុស	
៣០	ឯកឧត្តម ទាន់ ម៉ាត់	ប្រុស	
៣១	ឯកឧត្តម សេក សំអឿត	ប្រុស	
៣២	ឯកឧត្តម ប៉ើយ កើក	ប្រុស	
៣៣	ឯកឧត្តម ស៊ឹម កា	ប្រុស	
៣៤	ឯកឧត្តម ស៊ើយ កែវ	ប្រុស	
៣៥	ឯកឧត្តម សោម សុផា	ប្រុស	
៣៦	ឯកឧត្តម សួន លន់	ប្រុស	
៣៧	ឯកឧត្តម ស៊ុ គង់ទ្រីវ	ប្រុស	
៣៨	ឯកឧត្តម ហុង ឡុហាយ	ប្រុស	
៣៩	លោកជំទាវ ឡាក់ អូន	ស្រី	
៤០	ឯកឧត្តម ឡាវ ម៉េងឃីន	ប្រុស	
៤១	ឯកឧត្តម ឡាយ អ៊ីពិសិដ្ឋ	ប្រុស	
៤២	ឯកឧត្តម អ៊ុក គង់	ប្រុស	
៤៣	ឯកឧត្តម អ៊ុក ប៊ុនឈឿន	ប្រុស	
៤៤	ឯកឧត្តម អ៊ុំ សារិទ្ធ	ប្រុស	
៤៥	ឯកឧត្តម អ៊ុច ធី	ប្រុស	

២. គណបក្សហ៊ុនស៊ិនប៊ិច

ល.រ	គោត្តនាម-នាម	ភេទ	គណបក្ស
១	លោកជំទាវ ខ្លូត ឧចង្កា	ស្រី	
២	ឯកឧត្តម ជា គឹម	ប្រុស	
៣	ឯកឧត្តម អ៊ុច ហួត	ប្រុស	
៤	ឯកឧត្តម ឆ្លាំ ប៊ុនស្រុន	ប្រុស	

៥	សម្តេច ស៊ីសុវត្ថិ ជីវន័ធមុនីវង្ស	ប្រុស	
៦	ឯកឧត្តម ពៅ សិទ្ធិ	ប្រុស	
៧	លោកជំទាវ ម៉ែន ម៉ាលី	ស្រី	
៨	ឯកឧត្តម ប៉ុក កុសល	ប្រុស	
៩	ឯកឧត្តម ចៅ ប៊ុនស្រ៊ី	ប្រុស	
១០	ឯកឧត្តម ឈឹម សាខន	ប្រុស	

៣- គណបក្ស សម រង្ស៊ី

ល.រ	គោត្តនាម-នាម	តេង	គណបក្ស
១	ឯកឧត្តម គង់ គាំ	ប្រុស	
២	ឯកឧត្តម ទ៉ាន់ ស៊ីវឿន	ប្រុស	

៤- តំណាងព្រះមហាក្សត្រ

ល.រ	គោត្តនាម-នាម	តេង	តំណាងព្រះមហាក្សត្រ
១	ឯកឧត្តម អ៊ុំ ម៉ាឡូរីន	ប្រុស	
២	ឯកឧត្តម អឿត បណ្ណាការ	ប្រុស	

៥- តំណាងរដ្ឋសភា

ល.រ	គោត្តនាម-នាម	តេង	តំណាងរដ្ឋសភា
១	សម្តេចរាជបុត្រីព្រះរៀម នរោត្តម បុប្ផទេវី	ប្រុស	
២	ឯកឧត្តម សាប៉ី ឆាយ	ប្រុស	

១២. បញ្ជីរាយនាមសមាជិកា សមាជិកព្រឹទ្ធសភានីតិកាលទី២ តាមគណៈកម្មការ អក្សរឡាតាំង ឋានៈ

ថ្នាក់ដឹកនាំព្រឹទ្ធសភា

ល.រ	គោត្តនាម-នាម	អក្សរឡាតាំង	ឋានៈ
១	សម្តេច **ជា ស៊ីម**	Samdech CHEA SIM	ប្រធានព្រឹទ្ធសភា
២	សម្តេច **ស៊ីសុវត្ថិ ជីវ័ន្តមុនីរ៉ក្ស**	Samdech SISOWATH CHIVANMONIRAK	អនុប្រធានទី១
៣	ឯកឧត្តម **ទេព ងន**	H.E. TEP NGORN	អនុប្រធានទី២

១. គណៈកម្មការ សិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត

ល.រ	គោត្តនាម-នាម	អក្សរឡាតាំង	ឋានៈ
១	លោកជំទាវ **ម៉ែន ម៉ាលី**	H.E.Mrs. MEN MALY	ប្រធាន
២	ឯកឧត្តម **សេក សំអឿត**	H.E. SEK SAM-IET	អនុប្រធាន
៣	ឯកឧត្តម **គីម ណាំង**	H.E. KIM NAING	លេខាធិការ
៤	ឯកឧត្តម **កង ចន្ទ**	H.E. KANG CHAN	សមាជិក
៥	ឯកឧត្តម **អ៊ុក គង**	H.E. OK KONG	សមាជិក

២. គណៈកម្មការហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម

ល.រ	គោត្តនាម-នាម	អក្សរឡាតាំង	ឋានៈ
១	ឯកឧត្តម **ជា ជេដ្ឋ**	H.E. CHEA CHETH	ប្រធាន
២	ឯកឧត្តម **ពៅ សិទ្ធិ**	H.E. PEOU SITHIK	អនុប្រធាន
៣	ឯកឧត្តម **អ៊ុំ សារិទ្ធ**	H.E. UM SARITH	លេខាធិការ
៤	ឯកឧត្តម **វ៉ាន់ ម៉ាត់**	H.E. VAN MAD	សមាជិក
៥	ឯកឧត្តម **ឆាត់ លឿម**	H.E. CHHAT LOEUM	សមាជិក

៣. គណៈកម្មការ សេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧត្តុនិយម អភិវឌ្ឍន៍ជនបទ និង បរិស្ថាន

ល.រ	គោត្តនាម-នាម	អក្សរឡាតាំង	ឋានៈ
១	ឯកឧត្តម **ចាន់ ភិន**	H.E. CHAN PHIN	ប្រធាន
២	ឯកឧត្តម **អ៊ឹង ហួត**	H.E. UNG HUOT	អនុប្រធាន
៣	លោកជំទាវ **មាន សំអាន**	H.E.Mrs. MEAN SOMAN	លេខាធិការ
៤	ឯកឧត្តម **ជឹយ សាផុន**	H.E. CHEY SAPHON	សមាជិក
៥	ឯកឧត្តម **ម៉ុង ឬទ្ធី**	H.E. MONG REITHTHY	សមាជិក

៤. គណៈកម្មការ មហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈ

ល.រ	គោត្តនាម-នាម	អក្សរឡាតាំង	ឋានៈ
១	ឯកឧត្តម **គង់ សារាជ**	H.E. KONG SAREACH	ប្រធាន
២	ឯកឧត្តម **ប៊ុក កុសល**	H.E. ROS KOSAL	អនុប្រធាន
៣	ឯកឧត្តម **ឡាយ អ៊ីពិសិដ្ឋ**	H.E. LAY YPISITH	លេខាធិការ
៤	ឯកឧត្តម **រស់ ស្រេង**	H.E. ROS SRENG	សមាជិក
៥	ឯកឧត្តម **សឺយ កែវ**	H.E. SOEUY KEO	សមាជិក

៥. គណៈកម្មការ កិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន

ល.រ	គោត្តនាម-នាម	អក្សរឡាតាំង	ឋានៈ
១	លោកជំទាវ **ទី ប៊ូរ៉ាស៊ី**	H.E.Mrs. TY BORASY	ប្រធាន
២	ឯកឧត្តម **ជា គឹម**	H.E. CHEA KIM	អនុប្រធាន
៣	លោកជំទាវ **ឈូក ឈីម**	H.E. Mrs. CHHOUK CHHIM	លេខាធិការ
៤	ឯកឧត្តម **ទិត រាម**	H.E. TITH REAM	សមាជិក
៥	ឯកឧត្តម **ហុង ទូហាយ**	H.E. HONG TOUHAY	សមាជិក

៦. គណៈកម្មការ នីតិកម្ម និងយុត្តិធម៌

ល.រ	គោត្តនាម-នាម	អក្សរឡាតាំង	ឋានៈ
១	ឯកឧត្តម អ៊ុក ប៊ុនឈឿន	H.E. OUK BOUNCHHOEUN	ប្រធាន
២	ឯកឧត្តម យ៉ង់ សែម	H.E. YANG SEM	អនុប្រធាន
៣	ឯកឧត្តម ជា សុន	H.E. CHEA SON	លេខាធិការ
៤	ឯកឧត្តម ថុង ចន់	H.E. THONG CHON	សមាជិក
៥	ឯកឧត្តម បឿយ កើក	H.E. BOEUY KOEUK	សមាជិក

៧. គណៈកម្មការ អប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ និងទេសចរណ៍

ល.រ	គោត្តនាម-នាម	អក្សរឡាតាំង	ឋានៈ
១	ឯកឧត្តម គង់ គាំ	H.E. KONG KORM	ប្រធាន
២	ឯកឧត្តម ធ្លាំ ប៊ុនស្រុន	H.E. THOAM BUNSRON	អនុប្រធាន
៣	ឯកឧត្តម តូច សាក់	H.E. TOCH SAK	លេខាធិការ
៤	លោកជំទាវ ឡាក់ អួន	H.E. Mrs. LAK AUN	សមាជិក
៥	ឯកឧត្តម សោម សុផា	H.E. SOM SOPHA	សមាជិក

៨. គណៈកម្មការ សុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី

ល.រ	គោត្តនាម-នាម	អក្សរឡាតាំង	ឋានៈ
១	លោកជំទាវ ខ្លូត ទងផ្កា	H.E.Mrs. KHLOTH TONGPHKA	ប្រធាន
២	លោកជំទាវ ពុំ សុីចាន់	H.E.Mrs. PUM SICHAN	អនុប្រធាន
៣	ឯកឧត្តម សួន ឈន់	H.E. SUON LOAN	លេខាធិការ
៤	លោកជំទាវ ព្រុំ សុីត	H.E.Mrs.PRUM SORTH	សមាជិក
៥	ឯកឧត្តម វ៉ាន់ សុីវឿន	H.E.VANN SIVOEURN	សមាជិក

៩. គណៈកម្មការ សាធារណការ ដឹកជញ្ជូន អាកាសចរណ៍ស៊ីវិល ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបណីយកម្ម និងសំណង់

ល.រ	គោត្តនាម-នាម	អក្សរឡាតាំង	ឋានៈ
១	ឯកឧត្តម **សាប៊ូ ចាចា**	H.E. SABU BACHA	ប្រធាន
២	ឯកឧត្តម **ឈិត គីមយាត**	H.E. CHHIT KIMYEAT	អនុប្រធាន
៣	ឯកឧត្តម **ពុធ ខូវ**	H.E. PUTH KHOV	លេខាធិការ
៤	ឯកឧត្តម **អ៊ឹង ទី**	H.E. UNG TY	សមាជិក
៥	ឯកឧត្តម **ពុត ជួប**	H.E. PUTH CHUOP	សមាជិក

សមាជិកា សមាជិកព្រឹទ្ធសភាក្រៅគណៈកម្មការ

ល.រ	គោត្តនាម-នាម	អក្សរឡាតាំង	ឋានៈ
១	ឯកឧត្តម **អ៊ឹម មាន្នូរីន**	H.E. OUM MANNORINE	សមាជិក
២	ឯកឧត្តម **អៀវ បណ្ណាការ**	H.E. IEU PANNAKAR	សមាជិក
៣	ឯកឧត្តម **ឈា ថាំង**	H.E. CHHEA THANG	សមាជិក
៤	សម្តេចរាជបុត្រីព្រះវរៀម **នរោត្តម បុប្ផាទេវី**	SAMDECH NORODOM BOPHADEVI	សមាជិកា
៥	ឯកឧត្តម **ឡាវ ម៉េងឃីន**	H.E. SOM SOPHA	សមាជិក
៦	ឯកឧត្តម **ឈឹម សាខន**	H.E. CHHIM SAKHAN	សមាជិក
៧	ឯកឧត្តម **ម៉ែន សារុន**	H.E. MEN SARUN	សមាជិក
៨	ឯកឧត្តម **ស៊ី គង់ទ្រីវ**	H.E. SY KONGTRIV	សមាជិក
៩	ឯកឧត្តម **ស៊ីម កា**	H.E. SIM KA	សមាជិក
១០	ឯកឧត្តម **ប៉េង ផាត់**	H.E. PENG PHATH	សមាជិក
១១	ឯកឧត្តម **ពៅ ប៊ុនស្រឿ**	H.E. POR BUNSROEU	សមាជិក
១២	ឯកឧត្តម **កុក អាន**	H.E. KOK AN	សមាជិក
១៣	ឯកឧត្តម **លី យ៉ុងផាត់**	H.E. LY YONGPHAT	សមាជិក

១៣. សមាសភាពគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី២ (២០០៦-២០១២)



សម្តេច ស៊ីសុវត្ថិ ជីវ័ន្តមុនីវង្ស

អនុប្រធានទី ១ ព្រឹទ្ធសភា



សម្តេច ជា ស៊ីម

ប្រធានព្រឹទ្ធសភា



ឯកឧត្តម ទេព ចន

អនុប្រធានទី ២ ព្រឹទ្ធសភា



លោកជំទាវ ម៉ែន ម៉ាលី

ប្រធានគ. ទី ១



ឯកឧត្តម ជា ដេដ្ឋ

ប្រធានគ. ទី ២



ឯកឧត្តម ចាន់ តិន

ប្រធានគ. ទី ៣



ឯកឧត្តម គង់ សារាជ

ប្រធានគ. ទី ៤



លោកជំទាវ ទី ប៊ុនស៊ី

ប្រធានគ. ទី ៥



ឯកឧត្តម អ៊ុក ប៊ុនឈឿន

ប្រធានគ. ទី ៦



ឯកឧត្តម គង់ គាំ

ប្រធានគ. ទី ៧



លោកជំទាវ ខ្លូត ឧចង្កា

ប្រធានគ. ទី ៨



ឯកឧត្តម សាប៉ូ ឃាចា

ប្រធានគ. ទី ៩

១៤. សមាសភាព និងតួនាទី ភារកិច្ច និងសមត្ថកិច្ច របស់គណៈកម្មការជំនាញទាំង៩ ទីតិកាលទី ២ (២០០៦-២០១២)

គណៈកម្មការទី១ : សិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត



លោកជំទាវ ម៉ែន ម៉ាលី

ប្រធាន



ឯកឧត្តម សេក សំអឿត

អនុប្រធាន



ឯកឧត្តម គីម ណាំង

លេខាធិការ



ឯកឧត្តម កង ចន្ទ

សមាជិក



ឯកឧត្តម អ៊ុក គង់

សមាជិក

សមាសភាពលេខាធិការដ្ឋានអចិន្ត្រៃយ៍គណៈកម្មការ



លោក សុខ សុជាតិ

អនុប្រធានការិយាល័យទី១

០១១-៨៩២ ៦៩៣



កញ្ញា គង់ សុមនី

អនុប្រធានក្រុមលេខាធិការដ្ឋានជំនួយការ

០១២-៩២២ ៦៨៤



កញ្ញា នី រដ្ឋា

០១២-៣២១ ៧១៧



កញ្ញា អ៊ុក ចិន្តា

០១៦-៩៣៥ ៩៥៧

១. តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់គណៈកម្មការ សិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត

គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត អាចហៅកាត់ថា " គណៈកម្មការទី១" និងសរសេរជាអក្សរកាត់ថា "**គ.ស.ព.ប.អ**" ។

គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត នៃព្រឹទ្ធសភា មានតួនាទីដូចតទៅ :

ក-គាំទ្រលើកស្ទួយ និងការពារសិទ្ធិជនគ្រប់រូបឱ្យមានសេចក្តីថ្លៃថ្នូរ និងមានសិទ្ធិស្មើគ្នា ដើម្បីជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាព ក្នុងសង្គមជាតិ តំបន់ និងក្នុងសកលលោក ។

ខ-តាមដានត្រួតពិនិត្យនូវការអនុវត្តសិទ្ធិមនុស្សនៅកម្ពុជា ឱ្យបានសមស្របទៅតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងឯកសារបទដ្ឋានអន្តរជាតិទាំងឡាយក្នុងវិស័យសិទ្ធិមនុស្ស ដែលព្រះរាជាណាចក្រកម្ពុជាបានចូលរួមទទួលស្គាល់ ។

គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត នៃព្រឹទ្ធសភា មានភារកិច្ចដូចតទៅ :

ក-ការងារពាក្យបណ្តឹង :

- ទទួលពាក្យបណ្តឹងទូទៅពីបុគ្គល អ្នកតំណាង ក្រុម អង្គការ ឬសមាគមនានា
- ពិនិត្យពាក្យបណ្តឹង និងធ្វើការសម្របសម្រួល ដើម្បីស្វែងរកដំណោះស្រាយនៃបណ្តឹងនោះ ដោយធ្វើសហប្រតិបត្តិការជាមួយស្ថាប័ន ឬសមត្ថកិច្ចនានា ដោយផ្ទាល់ ឬតាមរយៈលិខិតស្នាម
- ចុះសិក្សាស្រាវជ្រាវជាក់ស្តែងនូវបញ្ហាស្តីពីការរំលោភសិទ្ធិមនុស្ស នៅតាមមូលដ្ឋាននានាដោយផ្ទាល់
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការស្រាវជ្រាវនោះ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍នៃព្រឹទ្ធសភា ឬលើកសំណូមពរទៅស្ថាប័ននានាដែលពាក់ព័ន្ធ ។

ខ-ការងារច្បាប់ :

- ផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ ដើម្បីអនុវត្តបទប្បញ្ញត្តិសិទ្ធិមនុស្សនានា ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងឯកសារសិទ្ធិមនុស្សអន្តរជាតិទាំងឡាយ ដែលកម្ពុជាបានចុះហត្ថលេខា
- ពិនិត្យ និងឱ្យយោបល់លើអត្ថបទច្បាប់ទាំងឡាយ ឬបញ្ហានានា ដែលរដ្ឋសភាបានអនុម័តជាលើកដំបូង ហើយដែលពាក់ព័ន្ធលើសិទ្ធិមនុស្ស
- ពិនិត្យមើលសាឡើងវិញនូវច្បាប់ទាំងឡាយ ដែលបានឬកំពុងអនុវត្ត ហើយដែលអាចនាំឱ្យចុះខ្សោយដល់ការលើកស្ទួយសិទ្ធិមនុស្សនៅព្រះរាជាណាចក្រកម្ពុជា

-ផ្តួចផ្តើមគំនិតធ្វើសិក្ខាសាលាជាសាធារណៈស្តីពីសេចក្តីស្នើច្បាប់ ឬអត្ថបទច្បាប់ ព្រមទាំងបញ្ហានានា ដែលពាក់ព័ន្ធនឹងវិស័យសិទ្ធិមនុស្ស ។

ត-ការអប់រំ និងផ្សព្វផ្សាយ :

សហការជាមួយស្ថាប័ន និងអង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធ ដើម្បីធ្វើការអប់រំ និងផ្សព្វផ្សាយអំពីសិទ្ធិមនុស្ស ជូនដល់ប្រជាពលរដ្ឋគ្រប់ៗរូប ។

ឃ-ការងារអង្កេត :

ក្រោយពីទទួលពាក្យបណ្តឹងនានា ត្រូវចុះធ្វើការអង្កេត ស្រាវជ្រាវឱ្យដល់ទីកន្លែងអំពីបាតុភាពមិនប្រក្រតីដែលកើតមានឡើង រួចធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការអង្កេត ស្រាវជ្រាវខាងលើដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍នៃព្រឹទ្ធសភា ។

គណៈកម្មការសិទ្ធិមនុស្ស ទទួពាក្យបណ្តឹង និងអង្កេតនៃព្រឹទ្ធសភា មានសមត្ថកិច្ចដូចតទៅ :

១-រាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍នៃព្រឹទ្ធសភា ឬព្រឹទ្ធសភាពេញអង្គនូវស្ថានភាពរំលោភសិទ្ធិមនុស្ស លើកសំណូមពរដើម្បីកែលំអ និងលើកស្ទួយការគោរពសិទ្ធិមនុស្ស ។

២-លើកសំណូមពរទៅរាជរដ្ឋាភិបាលលើបញ្ហានានា ដែលទាក់ទងទៅនឹងបញ្ហាសិទ្ធិមនុស្ស ។

៣-អង្កេត ស្រាវជ្រាវ ប្រមូលផ្តុំ និងវិភាគព័ត៌មាន ដើម្បីបញ្ជាក់ហេតុផលខាងរចនាសម្ព័ន្ធ ដែលបណ្តាលឱ្យមានការរំលោភសិទ្ធិមនុស្ស និងកំណត់ភ័ស្តុតាង វិធានការដោះស្រាយឱ្យមានប្រសិទ្ធភាពក្នុងគោលដៅលុបបំបាត់នូវបញ្ហានេះចោល ។

៤-ធ្វើការសម្របសម្រួលជាមួយរាជរដ្ឋាភិបាល ឬអាជ្ញាធរដែលពាក់ព័ន្ធ ដើម្បីចាត់វិធានការទប់ស្កាត់ការរំលោភសិទ្ធិមនុស្ស ។

៥-ចេញសេចក្តីរាយការណ៍ ឬសេចក្តីថ្លែងការណ៍ជាសាធារណៈ និងធ្វើការបញ្ជាក់លើបញ្ហាសិទ្ធិមនុស្ស ។

៦-ធ្វើសហប្រតិបត្តិការជាមួយអង្គការសិទ្ធិមនុស្សជាតិ និងអន្តរជាតិ ដើម្បីការពារ និងជំរុញសិទ្ធិមនុស្សក្នុងព្រះរាជាណាចក្រកម្ពុជា ។

៧-ស្វែងរកជំនួយថវិកា និងសម្ភារៈពីគ្រប់មជ្ឈដ្ឋាន សម្រាប់ដំណើរការលើកស្ទួយសិទ្ធិមនុស្ស និងការអង្កេតនៅកម្ពុជាឱ្យមានប្រសិទ្ធភាព ។

គណៈកម្មការទី២ : ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម



ឯកឧត្តម ជា ដេដ្ឋ

ប្រធាន



ឯកឧត្តម ពៅ សិទ្ធិ

អនុប្រធាន



ឯកឧត្តម អ៊ុំ សារិទ្ធ

លេខាធិការ



ឯកឧត្តម ង៉ាន់ ម៉ាត់

សមាជិក



ឯកឧត្តម ឆាត់ លៀម

សមាជិក

សមាសភាពលេខាធិការដ្ឋានរួមគណៈកម្មការ



លោក តុន តន្ធូ

អនុប្រធានការិយាល័យទី៣

០១២-៩១១ ១១៧



លោក ហ៊ួយ វ៉ាន់ឌី

អនុប្រធានក្រុមលេខាធិការដ្ឋានជំនួយការ

០១២-៨៣២ ៣៨២



លោកស្រី ជេត កណ្ណិកា

០១២-៧៧៥ ៩២២



កញ្ញា ហេង ច័ន្ទលេខា

០១៦-៧៧៩ ៩៥៩



លោក លី វីសាល

០១៦-២២២ ២១០

២. តួនាទីភារកិច្ច និងសមត្ថកិច្ច របស់គណៈកម្មការហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម

គណៈកម្មការហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម អាចហៅកាត់ថា "គណៈកម្មការទី២" និងសរសេរជាអក្សរកាត់ថា"**គ.ហ.ធ.ស**"។

គណៈកម្មការហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម មានតួនាទីសម្របសម្រួល ក្នុងបំណងការពារ និងលើកតម្កើងប្រសិទ្ធភាពនៃការប្រតិបត្តិច្បាប់ និងលិខិតបទដ្ឋានទាំងឡាយណា ដែលទាក់ទងទៅនឹងកិច្ចការហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម។

គណៈកម្មការហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម មានភារកិច្ចដូចតទៅ :

-សិក្សាស្រាវជ្រាវ ប្រមូលព័ត៌មាន ដែលទាក់ទងនឹងកិច្ចការជំនាញរបស់គណៈកម្មការហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ដើម្បីបំពេញភារកិច្ចសម្របសម្រួលការងារ

-សិក្សាស្រាវជ្រាវ និងតាមដានលើរាល់កិច្ចការ ដែលទាក់ទងសវនកម្មជាតិ និងកិច្ចការសវនកម្មផ្ទៃក្នុងរបស់ព្រឹទ្ធសភា

-ពិនិត្យ និងឱ្យយោបល់លើអត្ថបទច្បាប់ និងបញ្ហានានា ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

-ធ្វើសេចក្តីរាយការណ៍ និងការពារអត្ថបទច្បាប់ និងបញ្ហានានា ដែលបានពិនិត្យ និងឱ្យយោបល់ពីគណៈកម្មការជូនអង្គប្រជុំព្រឹទ្ធសភាពេញអង្គ

-សហការជាមួយប្រធានស្ថាប័ន ឬអ្នកធ្វើសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ ដើម្បីអញ្ជើញឱ្យចូលរួមធ្វើបាយការណ៍បំភ្លឺ និងការពារអត្ថបទច្បាប់

-ទទួលពិនិត្យ និងរកដំណោះស្រាយលើការតវ៉ាទាំងឡាយ ដែលទាក់ទងនឹងមុខជំនាញ ទៅតាមតួនាទីសមត្ថកិច្ចរបស់គណៈកម្មការហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ស្របទៅតាមក្របខណ្ឌអំណាចនីតិប្បញ្ញត្តិ

-កសាងគោលការណ៍ បទដ្ឋាន នីតិវិធីហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ដែលទាក់ទងនឹងថវិការបស់ព្រឹទ្ធសភា ដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍សម្រេច

-លើកផែនការថវិកា ត្រួតពិនិត្យ និងវាយតម្លៃលើការប្រើប្រាស់ថវិកាស្វយ័តរបស់ព្រឹទ្ធសភា។

គណៈកម្មការហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម មានសមត្ថកិច្ចក្នុងការពិនិត្យលើអត្ថបទច្បាប់ និងបញ្ហានានា និងលើកមតិជូនគណៈកម្មាធិការអចិន្ត្រៃយ៍ :

-អាចលើកចោលពុំពិចារណា

-បញ្ចេញមតិជាមុនថា តើគួរពិចារណា ឬមិនគួរ?

-ទទួលពិចារណា ហើយទុកជាការប្រញាប់ផងក៏បាន។

គណៈកម្មការទី៣ : សេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧត្តុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន



ឯកឧត្តម ចាន់ តិន

ប្រធាន



ឯកឧត្តម អ៊ឹង ហួត

អនុប្រធាន



លោកជំទាវ មាន សំអាន

លេខាធិការ



ឯកឧត្តម ជិយ សាផុន

សមាជិក



ឯកឧត្តម ម៉ុង ឫទ្ធី

សមាជិក

សមាសភាពលេខាធិការដ្ឋានអមគណៈកម្មការ



លោក ហង្ស ដារី

អនុប្រធានការិយាល័យទី៣

០១២-៨៧៥ ៥៧៥



លោក ហេង គីមហៃ

០១២-៧៧៧ ៤២៤



លោកស្រី សុខ សុខុណ្ណាវី

០១២-២២៧ ០៦៨



លោក ឧយ ម៉េងថារិទ្ធ

០១២-៧៧៨ ៧៨៨



លោក លីវ សេង

០១២-៨៩០ ២៧៧

៣. តួនាទី ភារកិច្ច និងសមត្ថកិច្ច របស់គណៈកម្មការសេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន

គណៈកម្មការសេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន អាចហៅកាត់ថា "គណៈកម្មការទី៣" និងសរសេរអក្សរកាត់ថា "គ.ស.ផ.វ.ក.ធ.ឧ.អ.ប" ។

គណៈកម្មការសេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន មានតួនាទីដូចតទៅ :

ក-ជាអ្នកជំនួយការឱ្យគណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភា ដែលពាក់ព័ន្ធទៅនឹងការងាររបស់ខ្លួន ។

ខ-សម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល ។

គ-សិក្សា ពិនិត្យខ្លឹមសារលើអត្ថបទច្បាប់ និងបញ្ហានានា ដែលគណៈកម្មាធិការអចិន្ត្រៃយ៍បញ្ជូនមក ។

គណៈកម្មការសេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន មានភារកិច្ចដូចតទៅ :

